លេខ.៦ ឆ្នាំ ២០១៧
Issue: 6 year 2017

CAMBODIA RICE FEDERATION

# ព្រឹត្តិបត្រព័ត៌មាន

" យើងរួមគ្នាលើកស្ទួយវិស័យស្រូវអង្ករ "





ចេញផ្សាយដោយ

**សហពន្ធ័ស្រូវអង្ករកម្ពុជា**

អាសយដ្ឋាន៖ អគារពាណិជ្ជកម្មសូម៉ា ជាន់ទី ៧
អាគារលេខ ២C ផ្លូវលេខ ១២០ សង្កាត់ ផ្សារថ្មី ॥
ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
គេហទំព័រ៖ www.crf.org.kh
សារអេឡិចត្រូនិក៖ info@crf.org.kh
ទូរស័ព្ទ៖ +៨៥៥ (0) ២៣ ៥៥៩ ៨៩៩៩
+៨៥៥ (0) ៨៧ ៥៥៩ ៨៩៩

និពន្ធ និងចងក្រងដោយ

ក្រុមការងារលេខាធិការដ្ឋានសហពន្ធ័ស្រូវអង្ករកម្ពុជា

ក្រុមហ៊ុនផ្សព្វផ្សាយពាណិជ្ជកម្ម

**ឧបត្ថម្ភធំដោយ**

SMWaypoint PRECISION REMOTE SENSING

នីកូលីន អ៊ិនវេសមេន ខូ., អិលធីឌី
NIKOLINE INVESTMENT CO., LTD

ANZ Royal


## មាតិកា


| | ទំព័រទី |
|---|---|
| សារឯកឧត្តម ប្រធានសហព័ន្ធ | ៣ |
| ការបោះឆ្នោតក្រុមប្រឹក្សាភិបាល និង សារឃោសនា | ៤-១១ |
| កិច្ចប្រជុំ លើកទី១ និង ការប្តេជ្ញារបស់ប្រធានគណៈកម្មាធិការប្រតិបត្តិ | ១២-១៤ |
| ការយកចិត្តទុកដាក់ចំពោះសហគមន៍កសិកម្មនិងសមាជិក | ១៥ |
| កូតានាំចេញអង្ករថ្មីពី ចិន វៀតណាម និង គោលដៅថ្មីៗ | ១៦- ១៧ |
| ការសម្របសម្រួលសមាជិកក្នុងព្រឹត្តិការណ៍អន្តរជាតិ | ១៨-២០ |
| ការសិក្សាបង្កើត«តែម» អង្ករសម្រាប់ទីផ្សារក្នុងស្រុក | ២១ |
| ការពង្រឹងការនាំចូលអង្ករពីប្រទេសជិតខាង | ២២-២៤ |
| ការងារតម្រង់ទិស លើគម្រោងជំរុញផលិតកម្មស្បៀង | ២៥ |
| Focusing On Model Farmland | ២៦- ២៧ |
| ការងារជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ធនាគារជាតិ | ២៨ |
| ស្ថាប័ននានាគាំទ្រ ការបែងចែកតំបន់ | ២៩- ៣១ |
| ការសហការជាមួយក្រុមហ៊ុនរដ្ឋចិន COFCO ក្នុងការនាំអង្ករទៅចិន | ៣២ |
| កិច្ចសហការនឹងកាំកុងត្រូលចុះពិនិត្យទំនិញអង្ករ | ៣៣ |
| MoU លើការងារបរិស្ថានជាមួយក្រសួងបរិស្ថាន | ៣៤- ៣៥ |
| ការងារជាមួយក្រសួងសាធារណៈការនិងដឹកជញ្ជូន | ៣៦ |
| មន្ត្រីសហភាពអឺរ៉ុបចុះពិនិត្យផ្ទាល់នៅសហគមន៍កសិកម្ម | ៣៧ |
| ការងារតាមដានតម្លៃស្រូវតាមតំបន់ | ៣៨ |
| ការងារតាមដានតម្លៃនាំចេញអង្ករ | ៣៩ |
| ទិន្នន័យនាំចេញអង្ករឆ្នាំ២០១៦ ធៀបបណ្តាឆ្នាំកន្លងមក | ៤០ |
| Making Rice More Nutritious | ៤២-៤៣ |


# សាររបស់ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា


ឯកឧត្តម **សុខ ពុទ្ធិវុធ**

ខ្ញុំសូមឆ្លៀតឱកាសនេះថ្លែងអំណរគុណដល់សមាជិកសហព័ន្ធស្រូវអង្ករកម្ពុជាទាំងអស់ ព្រមទាំងក្រុមប្រឹក្សាភិបាល និងក្រុមការងារ ជាពិសេសក្រុមការងារលេខាធិការដ្ឋានទាំងអស់ ដែលបានខំប្រឹងប្រែងជួយជំរុញនិងតាមដានការងាររបស់សហព័ន្ធ ជាមួយរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍និងក្រុមការងារផ្សេងៗ ក្នុងរយៈពេល ៣ឆ្នាំកន្លងមកនេះ៕ សហព័ន្ធស្រូវអង្ករកម្ពុជាបានស្វែងយល់និងដោះស្រាយបញ្ហាមួយចំនួន ដើម្បីជួយសម្រួលដល់ការលំបាក របស់វិស័យស្រូវអង្ករយើង។ ទោះបីជាមានការដោះស្រាយបញ្ហាស្រូវអង្ករយើងនៅគ្រប់ជាន់ថ្នាក់នៅក្នុងប្រទេសក្តី យើងនៅមានបញ្ហាគន្លឹះធំៗមួយចំនួនដែលយើងទាំងអស់គ្នាត្រូវចូលរួមគាំទ្រ និងដោះស្រាយរួមគ្នានៅលើចំនុចដូចខាងក្រោមនេះ៖

១- ពង្រឹងគុណភាព និងពង្រីកបរិមាណពូជស្រូវ
២- ពង្រឹងនិងពង្រីកសមត្ថភាពរបស់សហគមន៍កសិកម្ម និងការធ្វើកសិកម្មតាមកិច្ចសន្យា
៣- ជំរុញគម្រោងសម្ងួត និងឃ្លាំងស្តុកស្រូវ
៤ - រៀបចំនិងពង្រឹងទីផ្សារក្នុងស្រុក ក៏ដូចជាទីផ្សារអន្តរជាតិ
៥ - ការចងក្រង ប្រមូលទិន្នន័យដើម្បីងាយស្រួលធ្វើផែនការទីផ្សារ

ដោយសារយើងឯកភាពជំរុញយុទ្ធសាស្ត្រនាំចេញអង្ករដែលមានគុណភាពខ្ពស់នៅក្នុងរយៈពេលប្រាំឆ្នាំខាងមុខនេះ យើងត្រូវខិតខំប្រឹងប្រែងផលិតពូជស្រូវ អោយបានប្រមាណ ១០ម៉ឺនតោន ដែលប្រើប្រាស់ផ្ទៃដីប្រហែល ៣ម៉ឺនហិចតា។ យើងនឹងផ្តោតទៅលើពូជ៣លំដាប់ដែលរួមមានអង្ករក្រអូបផ្ការំដួល អង្ករសែនក្រអូប និងអង្ករស។

ដើម្បីជួយជំរុញការចូលរួមការចូលរួមពីសហគមន៍កសិកម្ម សហព័ន្ធស្រូវអង្ករកម្ពុជានឹងជួយធានាទីផ្សារជូនសហគមន៍ដែលមានបំណងចូលរួមជួយជំរុញកូតារបស់សហព័ន្ធស្រូវអង្ករកម្ពុជាក្នុងការនាំចេញអង្ករមានគុណភាពខ្ពស់ទៅកាន់ទីផ្សារក្នុងស្រុកនិងអន្តរជាតិ។ សហព័ន្ធស្រូវអង្ករកម្ពុជានឹងជួយជំរុញការធ្វើស្រែតាមកិច្ចសន្យាដើម្បីអភិវឌ្ឍស្តង់ដារល្អៗក្នុងការជួយធ្វើទំនើបកម្មវិស័យស្រូវនៅក្នុងពេលខាងមុខនេះ។

គម្រោងឃ្លាំងសម្ងួត និងឃ្លាំងស្តុកស្រូវ គឺជាគម្រោងដែលសំខាន់បំផុតសម្រាប់អនាគត វិស័យស្រូវអង្កររបស់យើងទាំងអស់គ្នា។ វាត្រូវការរៀបចំផែនការការងារឲ្យបានច្បាស់លាស់ រវាងរាជរដ្ឋាភិបាលនិងវិស័យឯកជននៅក្នុងវិស័យស្រូវអង្ករ។ដើម្បីជួយជំរុញនិងពង្រឹងការទុកចិត្តនៅក្នុងទីផ្សារក្នុងស្រុកក៏ដូចជាទីផ្សារអន្តរជាតិ។ សហព័ន្ធស្រូវអង្ករកម្ពុជាបានកំពុងតែរៀបចំការងារនៅមូលដ្ឋានដើម្បីចូលរួមរៀបចំដោះស្រាយការងារនៅមូលដ្ឋាន ជាមួយភាគីសំខាន់ៗក្នុងរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន។

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៧
**ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា**

**សុខ ពុទ្ធិវុធ**

## **មហាសន្និបាតៈ ការបោះឆ្នោត និង សារឃោសនារបស់ក្រុមប្រឹក្សាភិបាល និង រចនាសម្ព័ន្ធ**

### ការបោះឆ្នោតប្រធាននិងក្រុមប្រឹក្សាភិបាលសហព័ន្ធស្រូវអង្ករកម្ពុជា បង្ហាញពីការគាំទ្រដំណើរឆ្ពោះទៅមុខរបស់សហព័ន្ធស្រូវអង្ករកម្ពុជា។

លទ្ធផលបោះឆ្នោតប្រធាននិងក្រុមប្រឹក្សាភិបាលសហព័ន្ធស្រូវអង្ករក្នុងអាណត្តិទី២កាលពីខែកក្កដា ឆ្នាំ២០១៦ ដែលបានប្រកាសក្រោមវត្តមានដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី យឹម ឆៃលី** ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកម្មនិងជនបទ និង ឯកឧត្តមរដ្ឋមន្ត្រី ឯកឧត្តម រដ្ឋលេខាធិការ លោកជំទាវ ឧកញ៉ា លោក និង លោកស្រីតំណាងក្រសួងស្ថាប័នពាក់ព័ន្ធជាច្រើនរូបទៀតបានបង្ហាញឲ្យឃើញពីការគាំទ្រដំណើរការរបស់សហព័ន្ធស្រូវអង្ករកម្ពុជា និង ការបោះជំហានឆ្ពោះទៅមុខសម្រាប់ការកសាងស្ថាប័នតំណាងឲ្យវិស័យឯកជន ធ្វើការងារពាក់ព័ន្ធវិស័យស្រូវអង្ករឲ្យកាន់តែរឹងមាំ។

ការបោះឆ្នោតដែលរៀបចំឡើងដោយក្រសួងពាណិជ្ជកម្មកម្ពុជា ដឹកនាំដោយ**ឯកឧត្តម ម៉ៅ ថូរ៉ា** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្មជាការបោះឆ្នោតមួយប្រកបដោយតម្លាភាព សុក្រិត្យភាព និង យុត្តិធម៌សម្រាប់គ្រប់ភាគីដែលប្រកួតប្រជែងសម្រាប់តួនាទីជាប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា និង សមាជិកក្រុមប្រឹក្សាភិបាល។

លទ្ធផលឆ្នោតចុងក្រោយបានបង្ហាញឲ្យឃើញថា **ឯកឧត្តម សុខ ពុទ្ធិវុធ** នៅតែបន្តដឹកនាំសហព័ន្ធស្រូវអង្ករកម្ពុជាសម្រាប់អាណត្តិទី២ ដោយទទួលសំឡេងគាំទ្រចំនួន ១១៣ លើសគូរប្រកួតគឺលោក**ឧកញ៉ា តែ តាំងប៉រ** ដែលទទួលបានសំឡេងចំនួន៧៩ ក្នុងចំណោមអ្នកបោះឆ្នោតសរុប១៩២សម្លេង។

ក្រោយការរាប់សន្លឹកឆ្នោត និង ប្រកាសលទ្ធផលឆ្នោត ព្រមទាំង ទុកពេលតវ៉ាសម្រាប់គូប្រកួតប្រជែងដែលទទួលយកលទ្ធផលឆ្នោត **ឯកឧត្តម ម៉ៅ ថូរ៉ា** បានប្រកាសលទ្ធផលផ្លូវការ ក្រោមអធិបតីភាព **ឯកឧត្តម យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី និង ការចូលរួមពីថ្នាក់ដឹកនាំក្រសួងជាច្រើនរូប មានៈក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ក្រសួងធនធានទឹក និង ឧតុនិយម ព្រមទាំងតំណាងក្រសួង ស្ថាប័ន និង អង្គការជាដៃគូជាច្រើនរូបទៀត។

ក្រោយការប្រកាសលទ្ធផលជាផ្លូវការ **ឯកឧត្តម សុខ ពុទ្ធិវុធ** ដែលត្រូវបានសមាជិកសហព័ន្ធស្រូវអង្ករកម្ពុជា បោះឆ្នោតឲ្យធ្វើជាប្រធានសហព័ន្ធស្រូវអង្ករកម្ពុជាក្នុងអាណត្តិទី២ បានថ្លែងអំណរគុណដល់សមាជិក សមាជិកា ទាំងអស់របស់សហព័ន្ធស្រូវអង្ករកម្ពុជា ដែលបានខិតខំចំណាយពេលវេលាចូលរួមកម្មវិធី ព្រមទាំងគាំទ្រដល់ដំណើរការបោះឆ្នោតប្រកបដោយ យុត្តិធម៌។

**ឯកឧត្តម សុខ ពុទ្ធិវុធ** *បានថ្លែងថាៈ «ការបោះឆ្នោតគាំទ្រនេះ កាន់តែផ្តល់ទំនុកចិត្តដល់ខ្ញុំនិងសមាជិកក្រុមប្រឹក្សាភិបាលក្នុងអាណត្តិថ្មីកាន់តែទុកចិត្តក្នុងអាណត្តិថ្មីក្នុងការពុះពារដោះស្រាយបញ្ហាប្រឈមនានា ក្នុងវិស័យស្រូវអង្ករយើង»។*

ឯកឧត្តម ប្រធានសហព័ន្ធ បានបញ្ជាក់ថា វិស័យស្រូវអង្ករជាវិស័យមួយដែលមានទំនាក់ទំនងក្នុងជីវភាពរបស់ប្រជាជនកម្ពុជាយ៉ាងច្រើនព្រោះកម្លាំងពលកម្មរបស់ប្រទេសកម្ពុជាមួយភាគធំកំពុងពឹងផ្អែកក្នុងវិស័យនេះ។

ឯកឧត្តមបន្ថែមថាៈ«ខ្ញុំជឿជាក់ថាតម្រូវការអង្ករនឹងមិនថយឡើយ។យើងអាចអត់ឡានម៉ូតូបានតែយើងមិនអាចអត់អាហារបានទេ។ សម្រាប់ប្រទេសកម្ពុជាដែលអំណោយផលសម្រាប់ទឹកដី អាកាសធាតុ ភូមិសាស្រ្តផង គឺជាឱកាសសម្រាប់ប្រទេសយើងផ្គត់ផ្គង់អង្ករគុណភាពខ្ពស់ទៅបណ្តាប្រទេសនានាក្នុងពិភពលោក» ។

តាំងពីការចាប់ផ្តើមបង្កើនសហព័ន្ធស្រូវអង្ករម្លេះ ទស្សនៈវិស័យរបស់សហពព័ន្ធគឺ *"ការផ្តល់នូវអង្ករដែលមានតម្លៃ ប្រកួតប្រជែង និងគុណភាពខ្ពស់បំផុតដល់ពិភពលោក"។ ជាមួយទស្សនៈវិស័យនេះ សហព័ន្ធស្រូវអង្ករកម្ពុជាបានបោះជំហានទៅមុខប្រកបដោយសុទិដ្ឋិនិយម ប្រកបដោយការប្តេជ្ញាចិត្តខ្ពស់ក្នុងការគោរពលក្ខន្តិកៈរបស់ខ្លួន និង បានសហការជាមួយ ក្រសួងស្ថាប័នរដ្ឋ ដៃគូអភិវឌ្ឍន៍ ដើម្បីអនុវត្តផែនការសកម្មភាពនានា ក្នុងការជួយដល់សមាជិក និង វិស័យស្រូវអង្ករទាំងមូល។*

ការរួបរួមរបស់ផ្នែកឯកជនក្នុងឧស្សាហកម្មស្រូវអង្ករ ដែលបានបង្កើត "សហព័ន្ធស្រូវអង្ករកម្ពុជា" ជាលើកទីមួយ ក្នុងខែឧសភា ឆ្នាំ២០១៤ មិនត្រឹមតែជាសញ្ញាណបញ្ចប់នៃគំនិតប្រកួតប្រជែងផ្ទៃក្នុងដើម្បីរស់រានតែរៀងៗខ្លួននោះទេ តែថែមទាំងជំរុញកំណើនសម្រាប់វិស័យស្រូវអង្ករទាំងមូល តាមរយៈការសម្របសម្រួល ការសហប្រតិបត្តិការ និង ការចូលរួមក្នុងការសម្រេចចិត្តជាមួយរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដើម្បីរៀបចំគោលនយោបាយស្រូវអង្ករឲ្យកាន់តែឆ្លើយតបគ្រប់ស្ថានភាពទាំងក្នុងស្រុកនិងអន្តរជាតិ។

សហព័ន្ធស្រូវអង្ករកម្ពុជា យល់ច្បាស់ណាស់ថា ពាណិជ្ជកម្មអង្ករកម្ពុជាផ្តោតសំខាន់លើ «គុណភាព»។ តាមរយៈការទទួលបានជោគជ័យជាអន្តរជាតិ ដោយការឈ្នះនូវពានរង្វាន់អង្ករល្អបំផុតក្នុងពិភពលោករយៈពេលបីឆ្នាំជាប់ៗគ្នា គឺឆ្នាំ២០១២ ២០១៣ និង ២០១៤ កម្ពុជាបានក្លាយជាប្រទេសផលិតអង្ករដែលមានគុណភាព ដោយទទួលបានការដាក់សំគាល់ក្នុងផែនទីពិភពលោក ហើយ សហព័ន្ធស្រូវអង្ករកម្ពុជាពិតជាមានសុទិដ្ឋិនិយមចំពោះអនាគតស្រូវអង្ករកម្ពុជា។

សហព័ន្ធស្រូវអង្ករកម្ពុជាកើតឡើងដោយសមាជិកស្ថាបនិករទាំង២១៣រូបដែលមានតំណាងមកពីសហគមន៍កសិករ សមាគមរោងម៉ាស៊ីនកិនស្រូវនានា ក្រុមហ៊ុននាំចេញអង្ករ ក្រុមហ៊ុនដឹកជញ្ជូន វិស័យហិរញ្ញវត្ថុ ក្រោយការដាក់ចេញគោលនយោបាយស្រូវអង្កររបស់រាជរដ្ឋាភិបាលកម្ពុជាកាលពីឆ្នាំ២០១០៕



ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **យឹម ឆៃលី** និងថ្លែងក្រោយការប្រកាសលទ្ធផលបោះឆ្នោត



បេក្ខភាពប្រធាននិងក្រុមប្រឹក្សាភិបាលមុនពេលបោះឆ្នោត



ឯកឧត្តម **សុខ ពុទ្ធិវុធ** និង ឧកញ៉ា **តែ តាំងប៉** ក្នុងពេលបោះឆ្នោត

## សួស្តីប្រិយមិត្តអ្នកអានដែលតែងតាមដានព័ត៌មានសហព័ន្ធស្រូវអង្ករទាំងអស់ជាទីគោរពនិងជាទីមេត្រី។

លេខាធិការសហព័ន្ធស្រូវអង្ករកម្ពុជា មានកិត្តិយសសូមបង្ហាញជូននូវសារចំណាប់អារម្មណ៍របស់បេក្ខជនទាំងអស់ដែលឈរឈ្មោះប្រជែងយកតួនាទីក្នុងក្រុមប្រឹក្សាភិបាលរបស់សហព័ន្ធ នៅចំពោះមុខសមាជិក សមាជិក សហព័ន្ធស្រូវអង្ករកម្ពុជាដែលមានសិទ្ធិបោះឆ្នោតចំនួន១៩២នាក់ដែលមានវត្តមានចូលរួម ព្រមទាំងវត្តមានថ្នាក់ដឹកនាំ ភ្ញៀវកិត្តិយសជាតិនិងអន្តរជាតិ រួមទាំងអ្នកសារព័ត៌មានជាច្រើនរូបផ្សេងទៀត។

សាររបស់បេក្ខជននិមួយៗពិតជាមានខ្លឹមសារ ហើយក៏បង្ហាញពីការសន្យានិងការប្តេជ្ញាចិត្តសម្រាប់ការដឹកនាំសហព័ន្ធឆ្ពោះទៅរកភាពជោគជ័យនៅថ្ងៃអនាគត។ បេក្ខជនដែលបានឡើងប្តេជ្ញានានាពេលនោះ បច្ចុប្បន្នកំពុងកាន់តួនាទីសំខាន់ៗ ក្នុងសហព័ន្ធស្រូវអង្ករកម្ពុជាដែលជាតំណាងតែមួយគត់ក្នុងផ្នែកឯកជនដែលធ្វើសកម្មភាពស្របច្បាប់សម្រាប់លើកកម្ពស់វិស័យស្រូវអង្ករទាំងក្នុងកម្រិតជាតិនិងអន្តរជតិ។ **សូមបង្ហាញជូននូវខ្លឹមសាររបស់បេក្ខជនជាបន្តបន្ទាប់ដូចតទៅ!**

### សារទី១ ៖ លោក ឧកញ៉ា ហ៊ុន ឡាក់ ប្រធានក្រុមហ៊ុន មេគង្គ អូរីហ្សា ត្រេឌីង ខូអិលធីឌី ៖

«ខ្ញុំមានចំណាប់អារម្មណ៍ទៅអ្វីដែលប្រធាន [**សុខ ពុទ្ធីវុធ**] បានលើក គឺការសាមគ្គី។ ប្រសិនណាជាយើងមិនរួមគ្នាទេ យើងមិនងាយនឹង



ធ្វើកិច្ចការនេះជាមួយស្ថាប័នពាក់ព័ន្ធ ក៏ដូចជារាជរដ្ឋាភិបាលបានទេព្រោះកន្លងមកគត[រាជរដ្ឋាភិបាល] មានបញ្ហាលំបាក ដោយសារមានសំណើរចេញមកពីប្រភពខុសៗគ្នា ហើយបញ្ហានៃសំណើរនោះគឺស្រដៀងគ្នា។ ដូចនេះរដ្ឋាភិបាលមិនដឹងថា ខ្លួនត្រូវជួយដោះស្រាយជាមួយស្ថាប័នមួយណា។ កត្តារួមគ្នាគឺជាកត្តាស្លាប់រស់នៃសហព័ន្ធស្រូវអង្ករកម្ពុជា ក៏ដូចជាអ្នកពាក់ព័ន្ធក្នុងវិស័យស្រូវអង្ករទាំងមូល។ ខ្ញុំបានចាប់ផ្តើមមានគំនិត ហើយចាប់ផ្តើមបបួលឯកឧត្តម ប្រធាន [**សុខ ពុទ្ធីវុធ**] នៅមុនអាណត្តិទី១ ថា យើងគួរតែមានគំនិតមួយជួយដល់ជាតិ ហើយ លះបង់ព្រោះយើងមិនត្រូវការចំណេញ ឬ ទាញយកផលប្រយោជន៍អ្វីនោះទេ ដោយសារវិស័យកសិកម្មជាវិស័យអាទិភាពសម្រាប់យើងទាំងអស់គ្នា។ ប្រសិនយើងទាំងអស់គ្នាគិត ហើយ គិតតែឧស្សាហកម្មខ្នាតមធ្យមនិងធំ គឺគ្មាននរណាផ្សារភ្ជាប់ជាមួយកសិកម្មនោះទេ។ ចឹងទេ ប្រធានគាត់ថា គាត់តាំងចិត្ត។ ខ្ញុំសប្បាយចិត្តព្រោះប្រធានគាត់តាំងចិត្ត។ ជាទូទៅ ខ្ញុំពុំសូវឃើញថាកូនមន្ត្រីធំណា ហ៊ានលះបង់ ភាពងាយស្រួល ដោយសង្វើញជើងខោចុះជាមួយបងប្អូនកសិករ គឺគ្មានទេ!។ នេះគឺជាកត្តាដែលចេញមកពីឆន្ទៈដែលមានបេះដូង ដែលតាំង ចិត្តចង់ប្រឡូកក្នុងកិច្ចការងារនេះ។ ចឹងទេ ចំពោះខ្ញុំ ខ្ញុំផ្សារភ្ជាប់ជាមួយប្រធាន និង គាំទ្រទៅនឹងយុទ្ធសាស្ត្រផែនការរយៈពេលមធ្យមនិងវែង ហើយបច្ចុប្បន្នដាក់ចេញនូវផែនការរយៈពេលខ្លី ដើម្បីដោះនូវបញ្ហាដែលបងប្អូនកំពុងតែជួបប្រទះ។

បើសិនជាបងប្អូនមានចំណាប់អារម្មណ៍ឬក៏ជឿជាក់ ហើយផ្តល់ការទុកចិត្តខ្ញុំបានឈរជាសមាជិកក្រុមប្រឹក្សាភិបាលម្នាក់ ដើម្បីបន្តជួយមើលកិច្ចការងារទូទៅក្នុងសហព័ន្ធស្រូវអង្ករកម្ពុជាតាមរយៈក្រុមប្រឹក្សាភិបាល សូមបងប្អូនមេត្តាផ្តល់សន្លឹកឆ្នោតម្នាក់១សន្លឹក ដែលចូលចិត្តខ្ញុំ ក៏ដូចជាការផ្សារភ្ជាប់របស់ខ្ញុំទាំងប៉ុន្មានទៅដល់ឯកឧត្តមប្រធាន **ឯកឧត្តម សុខ ពុទ្ធីវុធ**!! សូមអរគុណ។

### សារទី២៖ ឧកញ៉ា ច្រាយ សុន ប្រធាន ក្រុមហ៊ុន

### CAPITAL FOOD INVESTMENT IMPORT EXPORT CO., LTD



[- - - គោលបំណងដែលខ្ញុំបាទឈរឈ្មោះជាបេក្ខជនសមាជិកក្រុមប្រឹក្សាភិបាលសហព័ន្ធស្រូវអង្ករកម្ពុជាក្នុងអាណត្តិនេះ យើងមានបំណងចង់ជួយដល់កសិករ ដែលកំពុងជួបនូវផលវិបាក បញ្ហាបច្ចេកទេស បញ្ហាពូជ បញ្ហាទីផ្សារ បញ្ហាទឹក -ល- ។ ដោយពិនិត្យឃើញថា រោងម៉ាស៊ីនកិនស្រូវរបស់យើងកំពុងមានស្ថានភាពធ្លាក់ចុះដុនដាបនឹងឈានទៅរកការក្ស័យធនជាបណ្តើរៗ ខ្ញុំសូមចូលរួមចំណែកទៅនឹងការងារនេះដើម្បីកែទម្រង់ កែសម្រួលឡើងវិញឲ្យឈានទៅរកការរីកចម្រើន ការដោះបំណុលគេឲ្យរួចខ្លួនតទៅទៀត។អាស្រ័យហេតុនេះ ខ្ញុំសូមសំណូមពរឲ្យឯកឧត្តម បងប្អូន ទាំងអស់ដែលបានចូលរួមក្នុងពិធីនេះ ដែលមានលទ្ធភាពបោះឆ្នោតដល់សមាជិកក្រុមប្រឹក្សាភិបាលនេះមេត្តាបោះឆ្នោតគាំទ្រខ្ញុំបាទ ដើម្បីឲ្យខ្ញុំបាទមានលទ្ធភាពចូលរួមប្រាស័យក្នុងសហព័ន្ធស្រូវអង្ករកម្ពុជាក្នុងអាណត្តិទី២នេះ---]។

### សារទី៣៖ លោក ឈិត ម៉ុនថន ប្រធាន រោងម៉ាស៊ីនកិនស្រូវ ឈិត ម៉ុនថន



ខ្ញុំបាទ **ឈិត ម៉ុនថន** សូមចូលរួមជាមួយក្រុមប្រឹក្សាភិបាលនៅក្នុងអាណត្តិទី២នេះ ដើម្បីជួយជំរុញ វិស័យស្រូវអង្ករនិង កសិកម្ម ក្នុងការនាំចេញ ដើម្បីធ្វើការងារដោយការរួបរួមគ្នា ដើម្បីជំរុញការនាំចេញរហូតដល់១លានតោន តាមផែនការរបស់រាជរដ្ឋាភិបាលឲ្យដល់គោលដៅ។ ដូចនេះ សូមបង ប្អូន ទាំងអស់គាំទ្រខ្ញុំបាទ មេត្តាបោះឆ្នោតឲ្យខ្ញុំបាទម្នាក់មួយសន្លឹក ដើម្បីឲ្យខ្ញុំបាទ បានជាប់ឈ្មោះ សូមអរគុណ!

### សារទី៤៖ លោក ប៉ូវ ណាម ប្រធាន រោងម៉ាស៊ីនកិនស្រូវ ណាម ស្រ៊ីម



សូមគោរព! ខ្ញុំបាទមកពីរោងម៉ាស៊ីនកិនស្រូវ **ណាម ស្រ៊ីម** ។ ខ្ញុំបាទឈរឈ្មោះជាសមាជិកក្រុមប្រឹក្សាភិបាលក្នុងអាណត្តិទី១ កន្លងមកហើយ។ កន្លងមក ខ្ញុំបាទបានចូលរួមជាមួយសហព័ន្ធពាក់ព័ន្ធ ការទំនាក់ទំនងទៅអាជ្ញាធរអគ្គិសនី ខាងពន្ធដារ ខាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ខ្ញុំបាទចង់ធ្វើនៅក្នុងអាណត្តិទី២ទៀត។ ចឹងបើបងប្អូនគាំទ្រខ្ញុំ មេត្តាបោះឆ្នោតឲ្យខ្ញុំ សូមអរគុណ!

### សារទី៥៖ ឧកញ៉ា ថាវ្យ ម៉ុនហេង ប្រធាន រោងម៉ាស៊ីនកិនស្រូវ ថាវ្យ ម៉ុន ហេង



ខ្ញុំបាទជាសមាជិកក្រុមប្រឹក្សាភិបាលចាស់ ហើយខ្ញុំក៏ឈរឈ្មោះជាសមាជិកក្រុមប្រឹក្សាភិបាលនៅអាណត្តិទី២។ ទិសដៅខ្ញុំដែលមកឈរសម្រាប់អាណត្តិទី២ នេះគឺខ្ញុំមានកិច្ចការត្រូវបង្ហើយក្នុងអាណត្តិទី១ ។ដោយសាររយៈពេលខ្លីពេកក្នុងអាណត្តិទី១ ខ្ញុំសុំឈរមួយអាណត្តិទៀត ដើម្បីបន្តកិច្ចការងាររបស់ខ្ញុំតទៅទៀត។ ទិសដៅរបស់ខ្ញុំមានពីរយ៉ាងធំៗគឺទី១៖ បង្រួបបង្រួមវិស័យស្រូវអង្ករទាំងអស់កុំឲ្យបែកបាក់គ្នា។ ទោះជាទៅយ៉ាងណាក៏ដោយ ក៏ខ្ញុំមិនចង់ឲ្យទៅដែរ គឺខ្ញុំចង់ឲ្យនៅមូលគ្នា។ បញ្ហាទី២៖ រិះរកថ្នាំដើម្បីព្យាបាលម៉ាស៊ីន កិនស្រូវ អ្នកនាំចេញ កសិករក្នុងវិស័យស្រូវអង្ករដែលកំពុងតែឈឺ ឲ្យបានជាសះស្បើយឡើងវិញ។ ថ្នាំដែលយើងចាប់ផ្តើមរកមានច្រើនយ៉ាង យើងមិនអាចយកទាំងអស់បានទេ យើងត្រូវយកម្តងមួយៗ ដូចជាបញ្ហាពន្ធដារ បញ្ហាពន្ធកាត់ទុក ពន្ធរលោះ ហើយ បញ្ហាបន្ទាប់ទៀតគឺបញ្ហាអគ្គិសនី។ កាលណាយើងមានអគ្គិសនីថោកហើយ យើងនឹងលែងព្រួយបារម្ភហើយ។ បញ្ហានេះគឺយើងអាចជជែកជាមួយគេបាន។ បញ្ហាទី៣៖ រឿងពាក់ព័ន្ធកម្ចីឬដើមទុន យើងចង់បានកម្ចីទុនដែលមានអត្រាការប្រាក់ថោក គឺយើងត្រូវរកវិធីទាំងប៉ុន្មាននោះសម្រាប់ដោះស្រាយ។ កាលណាយើងដោះស្រាយបាន គឺយើងរស់។ ម្យ៉ាងទៀត យើងត្រូវជំរុញរកវិធីសាស្ត្រយ៉ាងដូចម្តេច ដើម្បីឲ្យស្រូវពូជរបស់យើងមានតម្លៃថោក ព្រោះស្រូវពូជរបស់កម្ពុជាយើងសព្វថ្ងៃ មានតម្លៃថ្លៃណាស់។ ចឹងទេ យើងត្រូវរិះរកអង្គការណាដើម្បីជួយឧបត្ថម្ភ ឬដោយវិធីយ៉ាងណា ដើម្បីទទួលបានពូជនោះថោក។ ដោយសារពេលវេលាខ្លី ខ្ញុំមិនអាចអត្ថាធិប្បាយបានច្រើនអំពីវិធីជួយម៉ាស៊ីនកិនស្រូវ។ នៅទីនេះ សូមបង ប្អូនសំឡឹងមើលចំពោះអ្នកមកឈរនៅទីនេះ គឺសុទ្ធតែចង់ជួយទាំងអស់ ប៉ុន្តែសំខាន់បំផុត អ្នកណាមានពេលវេលាសម្រាប់ជួយវិស័យនេះ។ មិនមែនឈរខ្ពស់ហើយ ជាប់ហើយ បែជាគ្មានពេលវេលានោះទេ។ រិះរកមនុស្សណាដែលមានចំណេះដឹង មានពេលវេលាហ៊ាននិយាយទៅកាន់រាជរដ្ឋាភិបាលកម្ពុជា ឬអង្គការផ្សេងៗដើម្បីឲ្យជួយ បើសិនយើងមានតែមនុស្សណាដែលអត់មានជំនាញទៅនិយាយជាមួយអង្គការផ្សេងៗ និង ជួបថ្នាក់ដឹកនាំជាដើមគឺយើងនឹងលំបាក!។

## សារទី៦៖ លោក ឡាយ ឈុនហួ ប្រធានក្រុមហ៊ុន
## CITY RICE IMPORT EXPORT CO., LTD



ខ្ញុំជាជំនាន់ទី២នៃរោងម៉ាស៊ីនកិនស្រូវ **ឡាយ សែ**។ ថ្ងៃនេះបងៗមានចំណាប់អារម្មណ៍ក្នុងការកែប្រែ ដូចជាពាក់ព័ន្ធខាងពន្ធដារ ការដឹកជញ្ជូន និង ផ្នែកនាំចេញ។ ថ្ងៃនេះខ្ញុំឈរជាសមាជិកមួយ។ នៅក្នុងអាណត្តិទី១ យើងបានដោះស្រាយបញ្ហានៃការនាំចេញបានភាគច្រើនដោយកាត់បន្ថយនូវតម្លៃលើសេវាកម្មឯកសារពន្ធលើការដឹកជញ្ជូនជាដើម។ ចឹងទេ ក្នុងអាណត្តិទី២នេះ ខ្ញុំបាទមានគោលបំណងនិងចក្ខុវិស័យ៣ ដើម្បីដោះស្រាយជួយម៉ាស៊ីនកិនស្រូវម្តង។ ទី១៖ គឺថ្លៃអគ្គិសនី យើងឃើញថា ភ្លើងអគ្គិសនីចុះនៅកម្រិតទាបមែនទែន ០.១៧,២៥សេន ចុះមកនៅ០.១៦,៧៥សេន សម្រាប់ បងប្អូនមួយចំនួន ដែលប្រើភ្លើងត្រឹម១០ម៉ឺនគីឡូវ៉ាត់ម៉ោងចុះ។ ត្រឹមមួយខែគាត់សន្សំបានប្រមាណត្រឹម៥០០ ដុល្លារប៉ុណ្ណោះ។ បរិមាណនេះតូចណាស់សម្រាប់រោងម៉ាស៊ីនកិនស្រូវ។ ទី២៖ ខ្ញុំបាទ នឹងព្យាយាមពង្រឹងបន្ថែមចំពោះអង្ករនាំចូល ព្រោះបើយើងសំឡឹងឲ្យមែនទែនទៅ អង្ករដែលប្រើប្រាស់នៅក្នុងស្រុកមានប្រមាណ១,៥ លានទៅ២លានតោនក្នុងមួយឆ្នាំ។ បរិមាណនេះធំជាងការនាំចេញទៅកាន់បរទេស៤០០%។ចឹងទេអង្ករដែលនាំចូលមកទីផ្សារកម្ពុជាអាចកាត់បន្ថយម៉ាស៊ីនក្នុងស្រុកដែលតូចៗគឺអាចរស់បានភាគច្រើន។ ចំណែកទី៣៖ ខ្ញុំចង់ផ្សារភ្ជាប់រវាងកសិករនិងរោងម៉ាស៊ីនកិនស្រូវ និង ក្រុមហ៊ុនខ្ញុំផ្ទាល់ ក៏ដូចជារោងម៉ាស៊ីនទាំងអស់ គឺខ្ញុំនឹងខិតខំស្វែងរកទីផ្សារ ដើម្បីឲ្យរោងម៉ាស៊ីនតូចៗ ដែលគាត់គ្មានលទ្ធភាពនាំចេញផ្ទាល់ យើងអាចទិញអង្ករពាក់កណ្តាលសម្រេចក្នុងតម្លៃណាមួយដែលសមរម្យ ។ ក្នុងពេលកន្លងមកនេះ ខ្ញុំបានជួយទិញអង្ករផ្កាម្លិះនិងសែនក្រអូប ពីម្ចាស់រោងម៉ាស៊ីន ប្រហែល៥០រោងម៉ាស៊ីន ក្នុងបរិមាណចន្លោះពី៥ទៅ៧ពាន់តោន និងអង្ករពាក់កណ្តាលសម្រេចចន្លោះពី៣ទៅ៤ពាន់តោនទៀត។ ក្នុងរយៈពេលពីរឆ្នាំនេះ យើងបានរៀនសូត្រពីរទីផ្សារខាងក្រៅ ខ្ញុំសង្ឃឹមថា បងប្អូននឹងបោះឆ្នោតជូនខ្ញុំឲ្យនៅបន្តការស្វែងរកទីផ្សារនឹងដោះស្រាយបញ្ហាផ្សេងៗទៀត សូមអរគុណ!

## សារទី៧៖ លោក នង វាសនា នាយកផ្នែកទីផ្សារ នៃ ក្រុមហ៊ុន នីកូលីន អ៊ីនវេសមេន ខូអិលធីឌី



វិស័យស្រូវអង្ករជាវិស័យថ្មីស្រទន់ក្នុងមួយ ក្នុងចំណោមអាជីពពាណិជ្ជកម្មរបស់ខ្ញុំ ដែលខ្ញុំទើបតែប្រឡូកក្នុងវិស័យនេះ។ មូលហេតុដែលខ្ញុំបន្តឈរឈ្មោះជាសមាជិកក្រុមប្រឹក្សាភិបាល ដោយសារ ខ្ញុំចង់បន្តភាពខ្លាំងរបស់វិស័យស្រូវអង្ករនៅកម្ពុជា ដោយលើកកម្ពស់និងរក្សាតម្លៃអង្ករនៅកម្ពុជា។ មូលហេតុធំទី២ ខ្ញុំចង់ចូលរួមក្នុងចលនាមួយ គឺចលនាសាមគ្គីភាព រវាងអ្នករកស៊ីក្នុងអាជីពជាមួយគ្នា ទោះបីរោងម៉ាស៊ីន តូច កណ្តាល ឬធំ និងអ្នកនាំចេញ ដោយរក្សានូវសុចរិតភាព។ ការរក្សាសាមគ្គីភាពដោយជ្រកក្រោមឆ័ត្រតែមួយ គឺ សហព័ន្ធស្រូវអង្ករកម្ពុជា។ មូលហេតុទី៣ ខ្ញុំចង់ចូលរួមចំណែកក្នុងការរកទីផ្សារចំពោះអង្ករក្រអូប ដល់រោងម៉ាស៊ីនរបស់យើងទាំងអស់គ្នា ខណៈដែលរោងម៉ាស៊ីនធំនៅកម្ពុជាកំពុងប្រឈមទីផ្សារ។

## សារទី៨៖ លោក ហេង ផេង ប្រធាន ក្រុមហ៊ុន ថ្មគោលរ៉ាយស៍ អ៊ីមផត អ៊ិចផត



ខ្ញុំបាទជាសមាជិកក្រុមប្រឹក្សានៅក្នុងអាណត្តិចាស់។ ខ្ញុំឈរឈ្មោះសម្រាប់ក្រុមប្រឹក្សាភិបាលនៅអាណត្តិថ្មីនេះ ខ្ញុំចាប់អារម្មណ៍ពាក្យសាមគ្គីភាព។ សាមគ្គីភាព មានន័យថា បញ្ហាអ្វីៗ បញ្ហាប្រឈមនាពេលសព្វថ្ងៃនេះ មិនមែនមកពីបុគ្គលនេះឬបុគ្គលនោះ ធ្វើកើតឬមិនកើតនោះទេ។ វាជាបញ្ហារួមទាំងអស់។ កម្ពុជាយើងចូលដល់ទីផ្សារសេរី គេចូលយើង យើងក៏ត្រូវចូលគេដែរ។ យើងចូលសមាហរណកម្មសេដ្ឋកិច្ច តែវិស័យយើងនៅទន់ខ្សោយ។ អីចឹងទេ! យើងមិនទាន់មាន ចំណុចអ្វីមួយដែលយើងអាចការពារខ្លួនយើង កុំឲ្យគេចូលមក ដោយនិយាយរួមគឺ យើងនៅទន់ខ្សោយណាស់។ យើងមើលមិនឃើញថា ហេតុអ្វីបានជាសហព័ន្ធត្រូវការស្តង់ដារ។ ពីមុនយើងមិនដែលគិតសុវត្ថិភាព ឬ ស្តង់ដារអ្វីទាំងអស់ យើងគ្រាន់តែគិតថា អង្ករល្អ តម្លៃល្អ ក៏លក់ទៅ តែឥឡូវគឺខុសគ្នា។ យើងត្រូវដឹងថា ហេតុអ្វីបានជារោងម៉ាស៊ីននិមួយៗគេត្រូវការស្តង់ដា គឺ ដើម្បីជម្នះនូវរបាំងបើសិនជាយើងមានស្តង់ដារ យើងអាចនាំទៅគេបាន តែបើយើងគ្មានស្តង់ដារទេ បើទោះបីរបស់យើងល្អ ក៏យើងមិនអាចទៅរួចដែរ។ រហូតដល់ពេលនេះ យើងមានការងារពាក់ព័ន្ធជាមួយក្រសួងច្រើន ការងារពាក់ព័ន្ធនេះគឺសហព័ន្ធជាអ្នកដោះស្រាយ។ ដូចនេះយើងត្រូវតែរួមគ្នា ពេលដែលយើងរួមគ្នា យើងមានយុទ្ធសាស្ត្ររយៈពេលខ្លីនិងរយៈពេលវែង។ បញ្ហានៅបន្ទាប់ ក្រោយពេលយើងនៅជាមួយគ្នាហើយ យើងដឹងថាអ្នកណាអាចជាបង្គោល ដោះស្រាយបញ្ហារបស់យើងបាន។ ពេលនៅក្នុងអាណត្តិទី២នេះ សហព័ន្ធនឹងបង្កើតក្រុមការងារនៅតាមមូលដ្ឋាន ដើម្បីឲ្យបញ្ហារបស់អ្នករោងម៉ាស៊ីននៅតាមមូលដ្ឋានមានអ្នកដឹងឮ។ នាពេលបច្ចុប្បន្ន បញ្ហាកើតមាននៅផ្នែកខាងលើ គឺផ្នែកខាងលើដោះស្រាយបានច្រើន និង ធ្វើកើត។ ខ្ញុំមកនេះគឺខ្ញុំនឹងនាំនូវបញ្ហាកង្វល់របស់អ៊ុំៗ ពូៗ និងបងៗ មកកាន់សហព័ន្ធ។

## សារទី៩៖ លោក ឈុន ធំ ប្រធាន រោងម៉ាស៊ីនកិនស្រូវ ឈុន ធំ



ថ្ងៃនេះខ្ញុំឈានជើងចូលរួមប្រឡូកក្នុងសហព័ន្ធស្រូវអង្ករកម្ពុជាជាលើកទីមួយរបស់ខ្ញុំ។ ខ្ញុំមានគោលការណ៍បីសំខាន់។ ទី១៖ ខ្ញុំមានគោលបំណងចង់ផ្សារភ្ជាប់ កសិករជាមួយរោងម៉ាស៊ីន និង អ្នកនាំចេញ។ ទី២៖ ខ្ញុំមានបំណងចង់ជំរុញឲ្យឥណទាន សម្រាប់ជួយដល់រោងម៉ាស៊ីនកិនស្រូវ និង កសិករឲ្យបានលឿន ដូចលោកប្រធានបានលើក គឺខ្ញុំចង់ចូលរួមការងារជាមួយក្រុមប្រឹក្សាភិបាលនេះ។ ទី៣៖ ខ្ញុំចង់ឲ្យអ្នកនាំចេញ ធ្វើយ៉ាងម៉េចស្វែងរកទីផ្សារនៅក្រៅស្រុកឲ្យបានច្រើន ដើម្បីឲ្យរោងម៉ាស៊ីននៅក្នុងស្រុកយើងមានកូតាច្បាស់លាស់។

## សារទី១១៖ លោក តួ វាសនា ប្រធាន រោងម៉ាស៊ីនកិនស្រូវ អ៊ឹង វណ្ណាម៉ៅ



គោលការណ៍ដែលខ្ញុំឈរជាសមាជិកក្រុមប្រឹក្សាភិបាលក្នុងអាណត្តិថ្មី គឺចូលរួមដោះស្រាយបញ្ហាប្រឈមនានា ដែលពាក់ព័ន្ធនៅក្នុងវិស័យស្រូវអង្ករនេះ។ ដោយសារខ្ញុំជារោងម៉ាស៊ីនកិនស្រូវ ខ្ញុំជាអ្នកកម្ម៉ង់ទិញពីកសិករផ្ទាល់ រហូតដល់ការនាំចេញ ចឹងខ្ញុំអាចដឹងពីបញ្ហាប្រឈមផ្សេងៗទាំងអស់។ បញ្ហាប្រឈមដែលខ្ញុំចង់លើកឡើងក្នុងពេលនេះមានបីចំណុច៖ ទី១គឺទុន! ខ្ញុំនិងសមាជិករបស់សហព័ន្ធក្នុងអាណត្តិថ្មីនេះ នឹងចូលរួមស្វែងរកប្រភពទុនពីស្ថាប័នផ្សេងៗ ដែលអាចផ្តល់កម្ចីដល់រោងម៉ាស៊ីនកិនស្រូវក្នុងអត្រាការប្រាក់ទាប។ ទី២ គឺ ទីផ្សារ! បញ្ហាទីផ្សារនេះគឺយើងត្រូវធ្វើការងារនិងខិតខំរកប្រភពទីផ្សារ និង សម្រួលដល់អ្នកនាំចេញទាំងអស់ ដើម្បីទទួលបានអតិថិជនធំៗ ហើយនឹងចែកចាយបន្តទៅរោងម៉ាស៊ីនកិនស្រូវនៅតាមបណ្តាខេត្តទាំងអស់។ ទី៣ គឺបញ្ហាអង្ករវៀតណាម។ បញ្ហាអង្ករវៀតណាមនេះរដ្ឋាភិបាលបានបដិសេធ ហើយ តែការហូរចូលរបស់អង្ករវៀតណាមមានការកើនឡើង។ ទាំងបីចំណុចនេះ ខ្ញុំប្តេជ្ញាចិត្តលើកចូលទៅក្នុងប្រព័ន្ធ និង ដោះស្រាយជាបន្ទាន់។ ជាទីបញ្ចប់សូមសំណូមពរដល់ពូ មីងទាំងអស់ ជួយបោះឆ្នោតគាំទ្រដល់ខ្ញុំបាទផង!!! សូមអរគុណ

## សារទី១៣៖ លោក គឹម ប៊ុនសាន ប្រធានក្រុមហ៊ុន ខ្មែរហ្វ៊ីត គ្រុប



ខ្ញុំជាសំឡេងរបស់លោក**ឧកញ៉ា គឹម សាវុធ** ដែលជាអនុប្រធានសហព័ន្ធស្រូវអង្ករក្នុងអាណត្តិទី១។ គោលបំណងដែលខ្ញុំឈរជាសមាជិកក្រុមប្រឹក្សាភិបាលក្នុងអាណត្តិទី២នេះ គឺដើម្បីបន្តរកដំណោះស្រាយដល់បញ្ហាប្រឈមទាំងអស់ក្នុងអាណត្តិទី១ ដើម្បីជួយឲ្យវិស័យស្រូវអង្ករកាន់តែប្រសើរទៅមុខ។

## សារទី១៤. ឧកញ៉ា គុត ចាន់ថាសនា អគ្គនាយករង
## ក្រុមហ៊ុន CRYSTAL RICE (KAMPUCHEA) CO.,LTD



តាងនាមខ្ញុំជា រោងម៉ាស៊ីនកិនស្រូវគឺខ្ញុំទិញផលិតផលពីកសិករផ្ទាល់ និងកែច្នៃអង្ករខ្លួនឯងផង ព្រមទាំងនាំចេញខ្លួនឯងផង ហើយព្រមទាំងមានកំពង់ផែផ្ទាល់ខ្លួនសម្រាប់នាំផលិតផលចេញផង។ មូលហេតុដែលខ្ញុំឈរឈ្មោះជាសមាជិកក្រុមប្រឹក្សាភិបាលនៃសហព័ន្ធស្រូវអង្ករកម្ពុជាក្នុងអាណត្តិថ្មីនេះ គឺខ្ញុំចង់ផ្សារភ្ជាប់ពីបងប្អូនកសិករ ទៅដល់រោងម៉ាស៊ីនរហូតដល់ការនាំចេញ។ ហេតុផលទាំងអស់មានបីធំៗ ដែលខ្ញុំត្រូវដោះស្រាយគឺទី១ ស្រូវពូជ ការដាំដុះ និងធនធានទឹកផ្សេងៗ ដែលជាបញ្ហាប្រឈម របស់កសិករ។ បន្ទាប់មកទៀត គឺពាក់ព័ន្ធការកែច្នៃស្រូវអង្កររបស់យើងឲ្យមានគុណភាព ឲ្យត្រូវស្តង់ដារ ស្រូវពូជរបស់យើងឲ្យត្រូវស្តង់ដារ តាមគេចង់បាន។ ទី៣ គឺការនាំចេញ! ការនាំចេញយើងត្រូវធ្វើយ៉ាងដូចម្តេចឲ្យមានការសហការជាមួយរាជរដ្ឋាភិបាលដើម្បីរកទីផ្សារជូនដល់ប្រជាកសិករ។ សូមថ្លែងអំណរគុណ ហើយបើមានចំណាប់អារម្មណ៍ឲ្យខ្ញុំបានចូលរួមចំណែកក្នុងវិស័យស្រូវអង្ករនេះក្នុងអាណត្តិទី២នេះ។សូមជួយបោះឆ្នោតឲ្យខ្ញុំបាទផង!សូមអរគុណ!!!




## រចនាសម្ព័ន្ធថ្នាក់ដឹកនាំសហព័ន្ធអាណត្តិទី២



## សហព័ន្ធស្រូវអង្ករកម្ពុជាបើកកិច្ចប្រជុំដំបូងក្នុងអាណត្តិទី២ ស្នើបញ្ហាគន្លឹះៗទៅកាន់ក្រសួងពាណិជ្ជកម្ម

កិច្ចប្រជុំកុម្រប្រឹក្សាភិបាលសហព័ន្ធស្រូវអង្ករកម្ពុជាលើកដំបូង បានប្រព្រឹត្តិទៅក្រោមអធិបតីភាព លោកជំទាវ **សូ ស្រីម៉ិច** អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម និង ឯកឧត្តម **សុខ ពុទ្ធីវុធ** ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជាអាណត្តិថ្មី ដោយមានការអញ្ជើញចូលរួមពីសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ដែលបានជាប់ឆ្នោតកាលពីថ្ងៃទី២ខែកក្កដាឆ្នាំ២០១៦នេះ តំណាងសហគមន៍កសិកម្ម ព្រមទាំងមន្ត្រីក្រសួងពាណិជ្ជកម្មជាច្រើនរូបទៀត។ ថ្លែងនៅក្នុងឱកាសបើកកិច្ចប្រជុំក្រុមប្រឹក្សាភិបាល លោកជំទាវ **សូ ស្រីម៉ិច** អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម បានអបអរសាទរចំពោះឯកឧត្តម សុខ ពុទ្ធីវុធ និង សមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ដែលទទួលបានការទុកចិត្តពីសមាជិករបស់សហព័ន្ធស្រូវអង្ករកម្ពុជា ហើយ ត្រូវបានបោះឆ្នោតជ្រើសរើសជាប់ជាប្រធាន និង ក្រុមប្រឹក្សាភិបាលសម្រាប់អាណត្តិទី២នេះ។ ក្នុងឱកាសបើកកិច្ចប្រជុំលើកដំបូងនោះដែរ ឯកឧត្តម **សុខ ពុទ្ធីវុធ** ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា បានស្នើចំណុចសំខាន់ៗមួយចំនួនទៅកាន់ក្រសួងពាណិជ្ជកម្ម ដូចជា ៖

1. ស្នើសុំក្រសួង ជួយគាំទ្រនិងសម្រេច លើការស្នើសុំការចូលរួមសហការពីសហព័ន្ធ ក្នុងការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើម (ស៊ីអូ) ឲ្យក្រុមហ៊ុននាំចេញទាំងអស់ ត្រូវឆ្លងកាត់ការត្រួតពិនិត្យ ពីក្រុមហ៊ុនត្រួតពិនិត្យ គុណភាពអព្យាក្រឹត្យ ដែលបានទទួលស្គាល់ ដោយសហព័ន្ធ ដើម្បីពង្រឹងពីសមត្ថភាព ត្រួតពិនិត្យ របស់បណ្តាក្រុមហ៊ុន ត្រួតពិនិត្យ គុណភាពទាំងអស់លើការបញ្ជាក់ទាំងគុណភាព និង ប្រភពដើមអង្ករ។
2. ស្នើសុំក្រសួង ជួយពន្លឿនការចុះបញ្ជីម៉ាកបញ្ជាក់ពីចរិតលក្ខណៈទំនិញនិងសេវា ( Certification Mark ) ឈ្មោះអង្ករម្លិះ (Angkor Malis) ដើម្បីឲ្យសហព័ន្ធបន្តសកម្មភាព លើការផ្សព្វផ្សាយ ម៉ាកអង្កររបស់កម្ពុជា ការពង្រីកទីផ្សារ ការពារ និងធានានូវគុណភាពនិងកិត្តិយស កេរ្តិ៍អង្ករកម្ពុជា ទាំងក្នុងស្រុកនិងលើឆាកអន្តរជាតិ និង ការដាក់ពិន័យលើសមាជិកណាដែលប្រព្រឹត្តិ ផ្ទុយនឹងលក្ខខណ្ឌដែលបានចែង។
3. ស្នើសុំក្រសួង ពន្យាអាណត្តិរបស់សហព័ន្ធស្រូវអង្ករកម្ពុជាពីពីរទៅបួនឆ្នាំ តាមការអនុម័តដោយមតិភាគច្រើនរបស់ក្រុមប្រឹក្សាភិបាលសហព័ន្ធស្រូវអង្ករកម្ពុជា ក្នុងកិច្ចប្រជុំលើកដំបូង ដោយមូលហេតុរយៈពេលនៃការធ្វើការងារខ្លី ស្របពេលដែលបញ្ហាធំៗនានា កំពុងដោះស្រាយបន្តមិនទាន់ចប់។
4. ស្នើសុំក្រសួង ពិនិត្យលទ្ធភាពក្នុងការចេញនូវបទបញ្ញត្តិណាមួយដែលចែងថា «រាល់ការអនុញ្ញាតឲ្យនាំចូលអង្ករនិងការដាក់លក់លើទីផ្សារ ត្រូវមានព័ត៌មានអំពី អាសយដ្ឋាន ម៉ាកយីហោ និង ប្រភពច្បាស់លាស់ ដើម្បីពង្រឹងការនាំចូលអង្ករនិងគុណភាព អង្ករ ដែលបានចរាចរនៅលើទីផ្សារ
5. ស្នើសុំក្រសួង ជម្រុញការបង្កើនកូតានាំចូលប្រទេសចិន និង ការអនុញ្ញាតឲ្យសហព័ន្ធចុះ MoU ជាមួយ COFCO និងគម្រោងហិរញ្ញប្បទានពីប្រទេសចិនដើម្បីជម្រុញផលិតកម្មស្រូវនិងបង្កើនការនាំចេញអង្ករតាមរយៈការវិនិយោគឃ្លាំងស្តុក។
6. បញ្ហាផ្សេងៗ ពីវិស័យស្រូវអង្ករ

   ការពិភាក្សាស្តី ពីការជម្រុញការចុះបញ្ជីម៉ាកសំគាល់ភូមិសាស្ត្រទំនិញ (GI) ជំទាវ សូ ស្រីម៉ិច បានបញ្ជាក់ថា សម្រាប់អាណត្តិទី២នេះ សហព័ន្ធស្រូវអង្ករកម្ពុជា ត្រូវតែធ្វើផែនការឲ្យបានស៊ីជម្រៅ សម្រាប់ដោះស្រាយបញ្ហាស្រូវអង្កររយៈពេលខ្លី និង រយៈពេលវែង។ លើសពីនេះទៀត លោកជំទាវ បានសន្យាយកសំណើរទាំងអស់របស់សហព័ន្ធស្រូវអង្ករកម្ពុជាទៅជំរាបជូន ឯកឧត្តម រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មពិនិត្យនិងសម្រេច។



## ការប្តេជ្ញារបស់ប្រធានគណៈកម្មាធិការប្រតិបត្តិ

គណៈកម្មាធិការប្រតិបត្តិរបស់សហព័ន្ធស្រូវអង្ករកម្ពុជា ត្រូវបានប្រកាសសុពភាពសម្រាប់បំពេញការងាររបស់ខ្លួនសម្រាប់អាណត្តិទី២។ ខាងក្រោមនេះ គឺជាការប្តេជ្ញាចិត្តក្នុងការប្រតិបត្តិការងារ របស់ប្រធានគណៈកម្មាធិការនិមួយៗ នៅក្នុងឱកាសនៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកដំបូងបំផុតក្នុងអាណត្តិទី២ កាលពីថ្ងៃទី១២ខែកក្កដាឆ្នាំ២០១៦ កន្លងទៅនេះ។

### ឧកញ៉ា ហ៊ុន ឡាក់៖ ប្រធានគណៈកម្មាធិការប្រតិបត្តិឥណទានជាមួយធនាគារ



**ឧកញ៉ា ហ៊ុន ឡាក់៖** ក្រោយការបោះឆ្នោត តួនាទីបានធ្លាក់មកហើយ! ការរៀបចំសមាសភាពក្រុមការងារនៅក្នុងគណៈកម្មការនិមួយៗក៏ចាប់ផ្តើមដែរ។ បញ្ហាលុយជាបញ្ហាដែលក្តៅសម្រាប់អ្នកដែលមកមើលបញ្ហាលុយ ឬ ហិរញ្ញវត្ថុនេះ។ ពាក្យថាហិរញ្ញវត្ថុគឺត្រូវគិតគួររកប្រភពចំណូលយ៉ាងម៉េចមកដល់ស្ថាប័ន។ សម្រាប់ខ្ញុំ តើដែនសមត្ថកិច្ចនៃគណៈកម្មការនិមួយៗមានដាវអាជ្ញាសឹកមកពីណា? នេះជារឿងមួយដែលសំខាន់។ ខ្ញុំនឹងពិភាក្សាគ្នារកដៃគូរធ្វើការងារជាមួយគ្នា។យើងនឹងជជែកគ្នារឿងលុយកាក់នេះ ថាតើយើងត្រូវរកប្រភពឥណទានតាមវិធីណា តាមគ្រប់រូបភាពទាំងអស់ ដូចជា ធនាគារអភិវឌ្ឍន៍ជនបទឬធនាគារឯកជនដែលមាននូវបទបញ្ជាផ្ទៃក្នុងរបស់គាត់។ កិច្ចការងារនេះ ខ្ញុំនឹងគិតថា នឹងរៀបចំឲ្យមានទម្រង់ឯកសារ ឲ្យដើរស្របជាមួយនឹងធនាគារ ដែលគេតម្រូវឲ្យយើងធ្វើហើយចាប់ផ្តើមធ្វើកិច្ចការងារនេះដោយចុះទៅជួបជាមួយម្ចាស់រោងម៉ាស៊ីននានា ឬជាមួយសហគមន៍កសិករដែលបានប្រមូលផ្តុំគ្នាជាក្រុមធំៗ ដើម្បីជជែកគ្នារកវិធានការយ៉ាងដូចម្តេច ដើម្បីឲ្យចូលទៅក្នុងទម្រង់ដែលតម្រូវដោយភាគីធនាគារ និង រតនាគារជាតិ ព្រមទាំងការទទួលយកបានរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ។ បើយើងធ្វើកិច្ចការងារនេះ យើងត្រូវតែរួមគ្នាជួយដល់គំនិត យោបល់ ហើយ លើកយកបញ្ហាទាំងអស់ដាក់លើតុ រួចជជែកគ្នាទៅលើឧបសគ្គដែលយើងចង់ខ្ចីលុយពីធនាគារ ហើយ ធនាគារដាក់លក្ខខណ្ឌមក តែយើងទទួលយកមិនបាន ហើយ យើងចង់តវ៉ាយ៉ាងដូចម្តេច? ទាំងនេះសុទ្ធតែជាបញ្ហាដែលយើងត្រូវដាក់លើតុ ដើម្បីជជែកទាំងអស់គ្នា រួចធ្វើសំណើរទៅស្ថាប័នពាក់ព័ន្ធ។ បើសិនជាយើងតម្រូវទៅតាមបែបបទរបស់គេ ខ្ញុំជឿថា យើងអាចមានលទ្ធភាពទៅចរចារជាមួយគេ។ បើយើងមិនគិតគូរគ្នាយើងឲ្យបានស្រួលទេនិងទទួលយកទម្រង់ដែលជាតម្រូវការរបស់គេទេ ហើយលក្ខខណ្ឌនៃភាគីទាំងពីរមិនស្របគ្នា នោះជារឿងដែលលំបាក។

### ឧកញ៉ា ខង ម៉ិនហេង៖ ប្រធានគណៈកម្មាធិការទទួលបន្ទុកការប្រកួតប្រជែងតម្លៃថ្លៃដើម



**ឧកញ៉ា ខង ម៉ិនហេង ៖** ខ្ញុំសប្បាយចិត្តដែលបានជ្រើសរើសខ្ញុំជាប្រធានគណៈកម្មាធិការនេះ។ គណៈកម្មាធិការនេះមានរឿងធំតែមួយទេ គឺធ្វើម៉េចឲ្យតម្លៃថ្លៃដើមរបស់អង្កររបស់យើងថោកដែលអាចប្រកួតប្រជែងជាមួយអង្ករបរទេសបាន។ រឿងតម្លៃថ្លៃដើមចុះថោក គឺបែងចែកជាពីរ៖ ទី១ គឺយើងត្រូវខំធ្វើដោយខ្លួនឯង ដោយផ្តោតលើបច្ចេកទេស។ យើងត្រូវសិក្សាស្រាវជ្រាវទៅលើ ថាតើយើង ត្រូវធ្វើម៉េចដើម្បីឲ្យបានតម្លៃថ្លៃដើមដែលយើងមានខ្លួនឯងផ្ទាល់អាចកាត់បន្ថយបាន ដូចជា ការផលិតពូជ ការច្រូតកាត់ ការសម្ងួត ការកិននិងកែច្នៃអង្ករ ដើម្បីធ្វើម៉េចធានាការចំណាយកាន់តែតិច។នេះជារឿងដែលយើងត្រូវ

តែខិតខំធ្វើដោយខ្លួនឯង។ ទី២ គឺជារឿងដែលយើងត្រូវដើរចរចារជាមួយស្ថាប័នពាក់ព័ន្ធនានា ដើម្បីស្វែងរកលទ្ធភាពក្នុងការបញ្ចុះថ្លៃ ឬសន្សំសំចៃតម្លៃលើផ្នែកណាមួយ ឲ្យការផលិតស្ថិតនៅទាបតាមដែលអាចធ្វើបាន។ រឿងមានពីរនេះសំខាន់ណាស់សម្រាប់គណៈកម្មាធិការរបស់ខ្ញុំ៕

## លោក នង វាសនា៖ ប្រធានគណៈកម្មាធិការទទួលបន្ទុកការងាររោងម៉ាស៊ីន និង ឃ្លាំង



**លោក នង វាសនា:** សម្រាប់អាណត្តិថ្មីនេះ ខ្ញុំនឹងខិតខំបន្ថែមទៀត ដើម្បីទទួលបានការគាំទ្រពីបងប្អូនទាំងអស់គ្នា ដើម្បីទទួលបានព័ត៌មានពិតប្រាកដ។ ទី១៖ ខ្ញុំនឹងធ្វើការងារដើម្បីប្រមូលទិន្នន័យពីទិន្នផលស្រូវឲ្យបានជាក់លាក់ កុំឲ្យចេះតែថាដោយមិនពិតប្រាកដ។ ខ្ញុំសូមសំណូមពរឲ្យមានការចូលរួមយ៉ាងសកម្មពីបងប្អូនទាំងអស់គ្នា។ ទី២៖ ខ្ញុំនឹងខិតខំធ្វើការងារយ៉ាងជិតស្និទ្ធជាមួយគ្រប់ភាគីពាក់ព័ន្ធ រោងម៉ាស៊ីនកិនស្រូវ និង អ្នកកែច្នៃ ក្រុមហ៊ុននាំចេញជាដើម ដើម្បីពិភាក្សាគ្នារកដំណោះស្រាយពាក់ព័ន្ធការងារទាំងឡាយណាដែលពាក់ព័ន្ធការកែច្នៃ សមត្ថភាពនៃការផលិត និង ការស្តុកទុក។ ចំណុចទី៣៖ ខ្ញុំនឹងខិតខំធ្វើការងារជាជំហានៗ ដើម្បីប្រមូលព័ត៌មានជាក់លាក់រួចផ្តល់ព័ត៌មាននេះទៅកាន់សហព័ន្ធ ដើម្បីនាំយកព័ត៌មានទាំងនេះទៅជជែកជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីសម្របសម្រួលជាមួយស្ថាប័ននានាសម្រាប់រិះរកនូវយុទ្ធសាស្ត្រផ្សេងៗ និងកំណត់នូវផែនការសកម្មភាពផ្សេងៗ ដើម្បីស្តុកទុកវត្ថុធាតុដើមរបស់យើងឲ្យបានច្រើនបំផុតតាមដែលអាចធ្វើបាននៅពេលរដូវច្រូតកាត់។ ការស្តុកទុកនេះដើម្បីលក់ចែកចាយដល់រោងម៉ាស៊ីនកិនស្រូវ និង ក្រុមហ៊ុននាំចេញ។

## លោក ហេង ផេង៖ ប្រធានគណៈកម្មាធិការទទួលបន្ទុកការងារក្រមសីលធម៌និងវិន័យ



**លោក ហេង ផេង:** ខ្ញុំមានឱកាសមកដឹកនាំគណៈកម្មាធិការថ្មីនេះ។ រឿងនេះមិនមែនជារឿងតូចនោះទេ ព្រោះវាពាក់ព័ន្ធវិន័យនិងក្រមសីលធម៌។ ការប្រកួតប្រជែងមិនស្មើភាពនាំឲ្យបាត់ប្រយោជន៍ដល់កសិករ យើងត្រូវតែគិតប្រយោជន៍រួមទាំងអស់គ្នា។ គណៈកម្មាធិការផ្សេងៗមានផ្លូវរបស់ខ្លួនរួចជាស្រេចទៅហើយ។ ថ្មីៗនេះទៀត យើងនឹងព្យាយាមរិះរកនូវមធ្យោបាយផ្សេងៗ ដើម្បីស្នើទៅក្រសួងពាក់ព័ន្ធដើម្បីជួយយើង អំពីបញ្ហាការលាយអង្ករ ការទប់ស្កាត់ចំពោះការលួចបន្លំ ការប្រកួតប្រជែងមិនស្មើភាពគ្នា ដែលនាំទៅដល់ការបាត់បង់ប្រយោជន៍របស់សមាជិក និង ប្រជាជនទាំងអស់។ បើសិនជាយើងអត់ស្មោះត្រង់នឹងគ្នាទេគឺវាមិនមែនខាតចំពោះនរណាម្នាក់ទេ តែវាខាតទាំងអស់គ្នា។ ចឹងទេ អ្នកដែលស្រឡាញ់នឹងចូលចិត្តផ្នែកនេះ សូមជួយចូលរួមទាំងអស់គ្នា។ សម្រាប់ខ្ញុំ គណៈកម្មាធិការនេះថ្មី សូមឲ្យបងៗទាំងអស់គ្នាសូមជួយណែនាំផង ហើយ ខ្ញុំសូមប្តេជ្ញាថា ក្នុងអាណត្តិនេះ ខ្ញុំចូលរួមដាក់ចិត្តដាក់កាយឲ្យអស់ដើម្បីការងារស្រូវអង្ករ។៚

## លោក ស៊ី វ៉ានី៖ ប្រធានគណៈកម្មាធិការទទួលបន្ទុកការងារសហគមន៍កសិករនិងផលិតកម្មស្រូវពូជ



**លោក ស៊ី វ៉ានី:** សូមអរគុណចំពោះការទុកចិត្តខ្ញុំហើយផ្តល់ការងារឲ្យខ្ញុំកាន់កាប់ក្នុងអាណត្តិនេះ។ ថ្វីត្បិតតែការងារនេះមើលទៅធ្វើការងារតែជាមួយកសិករ តែទំហំការងារនេះពិតជាធំ ហើយវាជាលើកដំបូងហើយក៏ជារឿងថ្មីផងដែរសម្រាប់ខ្ញុំ។ ចំពោះខ្ញុំជាកសិករ ខ្ញុំនឹងធ្វើកិច្ចការជាមួយសហព័ន្ធនេះឲ្យបានច្រើនជាពិសេសជាមួយសហគមន៍ដែលជាក្រុមគោលដៅ។ យើងត្រូវធ្វើការងារដោយផ្តល់ទិន្នន័យទាំងចំនួនកសិករទាំងទំហំផ្ទៃដី និង ទិន្នផលរំពឹងទុក។ ពាក់ព័ន្ធពូជ ខ្ញុំគិតថា វាជារឿងសំខាន់មួយនៅក្នុងវិស័យស្រូវអង្ករ ដោយធ្វើយ៉ាងម៉េច យើងត្រូវផ្សព្វផ្សាយដល់កសិករឲ្យផលិតពូជសុទ្ធល្អ ហើយ តម្រូវការតាមទីផ្សារ ដែលសហព័ន្ធសង្ឃឹមទុកសម្រាប់ការកែច្នៃ និងផ្គត់ផ្គង់ដល់ទីផ្សារអន្តរជាតិ។ ក្នុងនាមជាកសិករនៅក្នុងសហគមន៍កសិកម្មដែលស្ថិតនៅក្រោមឆ័ត្ររបស់សហព័ន្ធ អ្វីដែលយើងត្រូវធ្វើការងារជាមួយគ្នាចែកជាបីផ្នែកសំខាន់ៗគឺអ្នកផលិត អ្នកកែច្នៃ និង អ្នកនាំចេញ។ ក្នុងនាមជាអ្នកផលិត ខ្ញុំនឹងខិតខំផលិតនិង ពង្រីកផ្ទៃដីដាំដុះដូចជាការបង្កើនរដូវជាដើម។ ចំពោះការផលិត យើងមិនត្រូវផ្តោតតែសម្រាប់ការហូបនោះទេ។ ចុងក្រោយគឺនិយាយពីពេលវេលាខ្ញុំនឹងខិតខំសម្រាប់កិច្ចប្រជុំនានាដែលសហព័ន្ធបានដាក់ចេញមកដើម្បីពង្រឹងការងាររបស់ខ្លួន។៚

# ការយកចិត្តទុកដាក់ជាមួយសហគមន៍កសិកម្ម

## ការចុះពិនិត្យបញ្ហាផ្ទាល់នៅមូលដ្ឋាន

ថ្នាក់ដឹកនាំរបស់សហព័ន្ធស្រូវអង្ករកម្ពុជាតែងតែយកចិត្តទុកដាក់ឆ្លើយតបចំពោះបញ្ហាដែលកើតមានជុំវិញបញ្ហាស្រូវអង្ករ។ ក្រោយពេលដែលប្រមូលផលស្រូវក្រអូបយ៉ាងច្រើន ស្របពេលអាកាសធាតុមិនអំណោយផលផងនោះ ថ្នាក់ដឹកនាំសហព័ន្ធស្រូវអង្ករកម្ពុជា ដឹកនាំដោយ **ឯកឧត្តម សុខ ពុទ្ធិវុធ** ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា បានចុះត្រួតពិនិត្យស្ថានភាពប្រមូលទិញស្រូវ និង ការប្រមូលផលស្រូវតាមសហគមន៍នៅខេត្តបន្ទាយមានជ័យ។

ប្រជាពលរដ្ឋ បានអះអាងថា សកម្មភាពប្រមូលផលស្រូវដើមរដូវ (ស្រូវក្រអូប) ដែលកំពុងតែប្រមូលផលយ៉ាងប្រញឹកបំផុតនាពេលនេះ ព្រោះក្តីបារម្ភខ្លាចទឹកភ្លៀងធ្លាក់មកខ្លាំងដែលអាចបណ្តាលឲ្យការខូចខាតកាន់តែធ្ងន់ធ្ងរ រីឯការទិញរបស់រោងម៉ាស៊ីនកិនស្រូវមានកម្រិត។

ការជួបជុំបានធ្វើឡើងនៅក្នុង សហគមន៍ពឹងពង់ ភូមិប្ញូរ ឃុំសឿ ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ ដោយមានវត្តមានចូលរួមរបស់ប្រធានមន្ទីរកសិកម្ម និង មន្ទីរពាណិជ្ជកម្មខេត្ត។

តាមសេចក្តីរាយការណ៍ពីកសិករ តម្លៃស្រូវបានធ្លាក់ចុះដល់ ៥៥០០បាត ក្នុងមួយតោននៅថ្ងៃទី២៨ខែកញ្ញាឆ្នាំ២០១៦។ តម្លៃនេះធ្លាក់ចុះប្រមាណ៥០%ធៀបនឹងស្រូវក្រអូបដែលប្រមូលផលនៅដើមរដូវក្នុងពាក់កណ្តាលខែសីហា។



សកម្មភាពចុះជួបសហគមន៍កសិកម្ម និងសមាជិករោងម៉ាស៊ីនកិនស្រូវនៅខេត្តបន្ទាយមានជ័យ និងខេត្តបាត់ដំបង

## កូតាថ្មីពីចិន វៀតណាម និង ត្រៀមប្រទេសមួយចំនួនទៀត

## កម្ពុជារំពឹងលើការពង្រីកទីផ្សារនៅក្នុងតំបន់កាន់តែធំទូលាយ

ជាមួយការផ្តល់កូតានាំចេញអង្ករផ្លូវការក្នុងពេលចុងឆ្នាំ២០១៦ ពីសំណាក់មហាអំណាចចិន និង ការផ្តល់កូតានាំចេញអង្ករទៅប្រទេសវៀតណាមក្នុងអត្រាពន្ធ0% កម្ពុជាក៏រក្សាលំនឹងក្នុងការនាំចេញទៅកាន់ទីផ្សារសហភាពអឺរ៉ុប ហើយ ក្រៅពីនេះមានទីផ្សារថ្មីៗនៃប្រទេសមួយចំនួនបានចែចូវចង់នាំចូលអង្ករពីប្រទេសកម្ពុជា។

ថ្មីៗនេះ ប្រទេសទីម័រឡេស្តេ ដែលជាប្រទេសទើបទទួលបានឯករាជ្យក្រោយគេបំផុតនៅតំបន់អាស៊ីភាគអាគ្នេយ៍ បានបង្ហាញពីបំណងទិញអង្ករពីប្រទេសកម្ពុជាក្នុងបរិមាណ២០០ពាន់តោនក្នុងមួយឆ្នាំ ខណៈទីផ្សារឥណ្ឌូនេស៊ីនៅតែស្ថិតនៅក្នុងក្តីរំពឹងទុកសម្រាប់ការនាំចេញអង្ករ ហើយក្រសួងពាណិជ្ជកម្មស្នើឲ្យសហព័ន្ធស្រូវអង្ករកម្ពុជាសិក្សាពីប្រភេទអង្ករនានា និង តម្លៃអង្ករសម្រាប់ត្រៀមប្រកួតប្រជែង។

នៅក្នុងកិច្ចប្រជុំពិភាក្សាស្តីពី «បរិមាណនិងប្រភេទអង្ករសម្រាប់ការនាំចេញក្នុងឆ្នាំ២០១៦-២០១៧» ក្រោមអធិបតីភាព **ឯកឧត្តម សុខ សុភ័ក្រ្ត** អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម និង **ឯកឧត្តម សុខ ពុទ្ធិវុធ** ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា មន្ត្រីជាន់ខ្ពស់ក្រសួងពាណិជ្ជកម្ម បានលើកឡើងថាការបើកទូលាយនៃទីផ្សារអង្ករកម្ពុជាសម្រាប់ឆ្នាំខាងមុននេះគឺជារឿងដែលសហព័ន្ធស្រូវអង្ករធ្វើការងាររួមគ្នាជាមួយក្រសួងពាណិជ្ជកម្មដើម្បីក្តាប់យកឱកាសនាំចេញអង្ករទៅបរទេស។

**ឯកឧត្តម សុខ សុភ័ក្រ្ត** អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម បានស្នើឲ្យសហព័ន្ធស្រូវអង្ករកម្ពុជា សិក្សានិងកំណត់អំពី យថាប្រភេទអង្ករថាតើ អង្ករកម្ពុជាមានប្រភេទអ្វីខ្លះ? តម្លៃប៉ុន្មាន? ដែលអាចនាំចេញទៅកាន់ប្រទេសឥណ្ឌូនេស៊ីក្នុងពេលណាមួយដែលភាគីកម្ពុជានិងឥណ្ឌូនេស៊ីមានកិច្ចព្រមព្រៀងរួចទៅហើយ។ ឯកឧត្តម បានបន្ថែមទៀតថា ប្រទេសទីម័រឡេស្តេ ក៏បានបង្ហាញពីបំណងនាំអង្ករចេញពីកម្ពុជាក្នុងបរិមាណ២០០ពាន់តោនក្នុងមួយឆ្នាំ នៅពេលដែលប្រមុខរាជរដ្ឋាភិបាលកម្ពុជាសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ដឹកនាំគណៈប្រតិភូទៅបំពេញទស្សនៈកិច្ចជាផ្លូវការនៅប្រទេសទីម័រឡេស្តេ កាលពីពេលថ្មីៗនេះ។ នៅពេលនោះឯកឧត្តមបានស្នើឲ្យសហព័ន្ធសិក្សាលើតម្លៃអង្ករ ដើម្បីឲ្យកម្ពុជាមានឱកាសប្រកួតប្រជែងជាមួយបណ្តាប្រទេសផ្សេងៗទៀត។

**ឯកឧត្តម សុខ ពុទ្ធិវុធ** ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា បានកត់សំគាល់ថា សហព័ន្ធស្រូវអង្ករកម្ពុជាមានបទពិសោធន៍គ្រប់គ្រាន់សម្រាប់ការចូលរួមធ្វើការងារនេះ ព្រោះការងារកន្លងមក ដូចជាទីផ្សារប្រទេសហ្វីលីពីនជាដើម បានក្លាយជាបទពិសោធន៍ក្នុងការចូលរួមដេញថ្លៃក្នុងការនាំអង្ករចេញ៕

*«នេះជាឱកាសល្អដែលយើងបានដឹងពីតម្រុយទីផ្សារនេះ ហើយ យើងនឹងព្យាយាមធ្វើផែនការនេះក្នុងពេលឆាប់ៗនេះ»។*

សម្រាប់ឆ្នាំពី២០១៦-២០១៧ ប្រទេសនាំចូលអង្ករមួយចំនួនបានសន្យាបង្កើនបរិមាណនាំចូលអង្ករពីប្រទេសកម្ពុជា ក្នុងនោះប្រទេសចិនបានសន្យាបង្កើនពី១០ម៉ឺនតោនទៅ២០ម៉ឺនតោន និង សញ្ញាណនាំចេញទៅកាន់ទីផ្សារអឺរ៉ុបនៅតែបង្ហាញពីភាពវិជ្ជមាន បើទោះបីប្រឈមការប្រកួតប្រជែងខ្ពស់។

នៅក្នុងកិច្ចប្រជុំនោះ **ឯកឧត្តម សុខ សុភ័ក្រ្ត** បានអំពាវនាវឲ្យសហព័ន្ធស្រូវអង្ករជួយសិក្សា ពីតម្លៃថ្លៃដើមអង្ករសម្រាប់នាំចេញ ដោយត្រូវកាត់បន្ថយតម្លៃថ្លៃដើម ឬតម្លៃដែលមិនចាំបាច់ត្រូវចំណាយណាមួយ ដើម្បីបន្ទាបតម្លៃអង្ករសម្រាប់ចូលរួមដេញថ្លៃជាមួយដៃគូប្រកួតប្រជែងផ្សេងៗទៀត។

*ឯកឧត្តម មានប្រសាសន៍៖ «យើងត្រូវរកវិធីដោះស្រាយរឿងបញ្ហាតម្លៃ ព្រោះតម្លៃទាំងនោះមិនមែនជាតម្លៃដែលយើងមិនមែនបញ្ហាមិនបាននោះទេ»។*

វៀតណាមផ្តល់ការអនុគ្រោះពន្ធអត្រា0%ដល់ការនាំចូលអង្ករពីកម្ពុជា កាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៦ នៅរដ្ឋធានីហាណូយ ប្រទេសវៀតណាម ក្នុងឱកាសបំពេញទស្សនៈកិច្ចជាផ្លូវការ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់ក្នុងជួរនៃរាជរដ្ឋាភិបាល និង អ្នកធុរកិច្ចទៅបំពេញទស្សនៈកិច្ចនិងចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្ម។ កិច្ចជំនួបនេះជាផ្នែកមួយនៃ







កិច្ចប្រជុំកំពូលយុទ្ធសាស្រ្តសហប្រតិបត្តិការសេដ្ឋកិច្ច អាយ៉េយ៉ាវ៉ាឌី ចៅផៅយ៉ាមេគង្គ (ACMECS) លើកទី ៧ និងកិច្ចប្រជុំកំពូលកម្ពុជា ឡាវ មីយ៉ាន់ម៉ា និង វៀតណាម (CLMV) លើកទី ៨ ព្រមទាំងកិច្ចប្រជុំវេទិកាសេដ្ឋកិច្ចពិភពលោក (WEF) ស្តីពីតំបន់មេគង្គ។ នាពេលនោះ វៀតណាមអនុញ្ញាតឲ្យកម្ពុជានាំចូលសន្លឹកថ្នាំជក់ស្ងួត និងអង្ករ ដោយឥតបង់ពន្ធជារៀងរាល់ឆ្នាំ។ យោងតាមខ្លឹមសារនៃកិច្ចសម្របសម្រួលបានឲ្យដឹងថា ភាគីកម្ពុជាយល់ព្រមផ្តល់ភាពអនុគ្រោះពន្ធ 0% (សូន្យភាគរយ) នូវមុខទំនិញចំនួន ២៩បន្ទាត់ពន្ធដល់ភាគីវៀតណាម ហើយភាគីវៀតណាម យល់ព្រមផ្តល់ភាពអនុគ្រោះពន្ធ 0% (សូន្យភាគរយ) នូវមុខទំនិញចំនួន ៣៩បន្ទាត់ពន្ធដល់ភាគីកម្ពុជាវិញ ដោយរួមបញ្ចូលមុខទំនិញអង្ករចំនួន ៣០ម៉ឺនតោន រៀងរាល់ឆ្នាំ និងសន្លឹកថ្នាំជក់ស្ងួតចំនួន ៣ពាន់តោន សម្រាប់ឆ្នាំ២០១៦-២០១៧។

កិច្ចសម្របសម្រួលជំរុញពាណិជ្ជកម្មទ្វេភាគីរវាងប្រទេសទាំងពីរ បានធ្វើឡើងរវាង **ឯកឧត្តម ប៉ាន សូរស័ក្តិ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មកម្ពុជា និងលោកត្រាន ទួនអាញ (Tran Tuan Anh) រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្ម វៀតណាម នាព្រឹកថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៦ នៅរដ្ឋធានីហាណូយ ប្រទេសវៀតណាម។
ពិធីចុះហត្ថលេខានេះ បានប្រព្រឹត្តិទៅក្រោមអធិបតីភាពលោកហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង លោកង្វៀន សួនហ៊្វុក (Nguyen Xuan Phuc) នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម៕

ជាមួយការផ្តល់កូតានាំចេញអង្ករផ្លូវការក្នុងពេលចុងឆ្នាំ២០១៦ ពីសំណាក់មហាអំណាចចិន និង ការផ្តល់កូតានាំចេញអង្ករទៅប្រទេសវៀតណាមក្នុងអត្រាពន្ធ0% កម្ពុជាក៏រក្សាលំនឹងបានក្នុងការនាំចេញទៅកាន់ទីផ្សារសហភាពអឺរ៉ុប ហើយ ក្រៅពីនេះមានទីផ្សារថ្មីៗនៃប្រទេសមួយចំនួនបានចែចូវចង់នាំចូលអង្ករពីប្រទេសកម្ពុជា។

ថ្មីៗនេះ ប្រទេសទីម័រឡេស្តេ ដែលជាប្រទេសទើបទទួលបានឯករាជ្យក្រោយគេបំផុតនៅតំបន់អាស៊ីភាគអាគ្នេយ៍ បានបង្ហាញពីបំណងទិញអង្ករពីប្រទេសកម្ពុជាក្នុងបរិមាណ២០០ពាន់តោនក្នុងមួយ ឆ្នាំ ខណៈទីផ្សារឥណ្ឌូនេស៊ីនៅតែស្ថិតនៅក្នុងក្តីរំពឹងទុកសម្រាប់ការនាំចេញអង្ករ ហើយក្រសួងពាណិជ្ជកម្មស្នើឲ្យសហព័ន្ធស្រូវអង្ករកម្ពុជាសិក្សាពីប្រភេទអង្ករនានា និង តម្លៃអង្ករសម្រាប់ត្រៀមប្រកួតប្រជែង។ យោងតាមការអះអាងរបស់មន្ត្រីជាន់ខ្ពស់ក្រសួងពាណិជ្ជកម្ម។

## សម្របសម្រួលជាមួយសមាជិកចូលរួមសកម្មភាពផ្សេងៗ

## ការចូលរួមផ្សព្វផ្សាយក្នុងទីផ្សារអន្តរជាតិ «ពិព័រណ៍ចិន-អាស៊ាន លើកទី១៣»

ក្នុងឱកាសនៃការប្រារព្ធពិព័រណ៍ចិន-អាស៊ាន លើកទី១៣ និងវេទិកាស្តីពីពាណិជ្ជកម្ម និងវិនិយោគកម្ពុជា-ចិន លើកទី១នៅព្រឹកថ្ងៃទី១១ខែកញ្ញាឆ្នាំ២០១៦នៅទីក្រុងណាននីងខេត្តក្វាងស៊ីសាធារណៈរដ្ឋប្រជាមានិតចិនថ្នាក់ដឹកនាំនិងមន្ត្រីលេខាធិការដ្ឋានជាច្រើនរូបបានចូលរួម និង យកផលិតផលអង្ករកម្ពុជាជាច្រើនម៉ាកទៅចូលរួមតាំងពិព័រណ៍នៅទីនោះ។

នៅក្នុងការរៀបចំព្រឹត្តិការណ៍ពិព័រណ៍ដ៏ធំប្រជាចំតំបន់អាស៊ីនេះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់កម្ពុជា រួមមានថ្នាក់ដឹកនាំក្រសួងនានា និង វិស័យឯកជនរួមមានគណៈប្រតិភូសភាពាណិជ្ជកម្មកម្ពុជា និង សហព័ន្ធស្រូវអង្ករកម្ពុជា ទៅចូលរួមព្រឹត្តិការណ៍ដ៏សំខាន់នេះក្នុងបំណងទាក់ទាញទីផ្សារចិនទិញផលិតផលខ្មែរឲ្យបានបន្ថែមទៀត និង ទាក់ទាញវិនិយោគិនបរទេសជាពិសេសចិនបន្តបណ្តាក់ទុនវិនិយោគនៅកម្ពុជា។

**ឯកឧត្តម សុខ ពុទ្ធីវុធ** ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជាបានដឹកនាំ ក្រុមប្រឹក្សាភិបាល និង មន្ត្រីលេខាធិការដ្ឋានទៅចូលរួមពិព័រណ៍ និង វេទិកាពាណិជ្ជកម្ម និង វិនិយោគកម្ពុជាចិន លើកទី១ First Cambodia-China Business and Investment Forum នៅទីក្រុងណាននីង ខេត្តក្វាងស៊ីប្រទេសចិន នៅថ្ងៃទី១២កញ្ញា ឆ្នាំ២០១៦។

យ៉ាងហោចណាស់ក្រុមហ៊ុនរោងម៉ាស៊ីនកិនស្រូវដែលកំពុងប្រតិបត្តិការកិនស្រូវ កែច្នៃ និង នាំចេញអង្ករចំនួន៧ រួមជាមួយសហព័ន្ធស្រូវអង្ករកម្ពុជា (CRF) នឹងមានវត្តមានចូលរួមពិព័រណ៍ និង វេទិកាពាណិជ្ជកម្ម ចាប់ពីថ្ងៃទី១១ ដល់ថ្ងៃទី១៤ ខែ កញ្ញា ឆ្នាំ២០១៦ នៅទីក្រុងណាននីងខេត្តក្វាងស៊ីប្រទេសចិន។







## ការចូលរួមសន្និសីទស្រូវអង្ករអន្តរជាតិ ( The World Rice Conference )

ជារៀងរាល់មួយឆ្នាំម្តង សន្និសីទស្រូវអង្ករអន្តរជាតិតែងតែរៀបចំព្រឹត្តិការណ៍ប្រចាំឆ្នាំរយៈពេលពីរថ្ងៃ ដោយមានវត្តមានចូលរួមពីសំណាក់អ្នកពាក់ព័ន្ធដែលមានជីវកម្មក្នុងវិស័យស្រូវអង្ករ មកពីជុំវិញពិភពលោក។
សន្និសីទស្រូវអង្ករអន្តរជាតិនៅខេត្តឈៀងម៉ៃប្រទេសថៃ បានទាក់ទាញអ្នកចូលរួមជាង៣០០នាក់ដែលសុទ្ធសឹងជាអ្នកជំនួញនិងអ្នកផលិតយ៉ាងសកម្ម មកពីគ្រប់តំបន់ ដូចជា តំបន់អាស៊ីជាតំបន់ផលិតសំខាន់ តំបន់អឺរ៉ុបជាតំបន់នាំចូលនិងប្រើប្រាស់ តំបន់អាមេរិកជាតំបន់ផលិតផងនិងប្រើប្រាស់ផង និង ពីតំបន់ផ្សេងៗទៀត។

សហព័ន្ធស្រូវអង្ករកម្ពុជា និងសមាជិករបស់ខ្លួនតែងតែចូលរួមព្រឹត្តិការណ៍នេះ ដោយនាំយកនូវព័ត៌មានចុងក្រោយបំផុតពាក់ព័ន្ធស្រូវអង្ករដើម្បីបង្ហាញជូនអ្នកចូលរួម តាមរយៈបទបង្ហាញនិងការចូលរួមពិភាក្សាទ្វេភាគី។ លើសពីនេះ ក្រុមហ៊ុននានាដែលជាសមាជិករបស់សហព័ន្ធស្រូវអង្ករកម្ពុជា ក៏បានចាត់ទុកព្រឹត្តិការណ៍ប្រចាំឆ្នាំនេះមានសារៈសំខាន់ក្នុងការស្វែងរកដៃគូពាណិជ្ជកម្មថ្មីៗសម្រាប់ពង្រីកទីផ្សារអង្កររបស់ខ្លួន។

ក្រៅពីជំនួបសម្រាប់វិស័យពាណិជ្ជកម្មស្រូវអង្ករ សន្និសីទស្រូវអង្ករក៏បានរៀបចំប្រកួតគុណភាពអង្ករតាមរយៈការចម្អិនបាយដោយចុងជំនាញៗ។ការប្រកួតគុណភាពអង្ករដ៏មានប្រជាប្រជាប្រិយនេះតែងទាក់ទាញនូវការចឹងដឹងពីសំណាក់ប្រជាជនដែលផលិតអង្ករ។ជានិច្ចកាល ប្រទេសដែលដាក់ការប្រកួតប្រជែងគុណភាពអង្ករ រួមមាន៖ កម្ពុជា ថៃ វៀតណាម មីយ៉ាន់ម៉ា ប៉ាគីស្ថាន ឥណ្ឌា និង សហរដ្ឋអាមេរិកដែលមានអង្ករសរុបជាង២០សំណាក។

សម្រាប់ការប្រកួតគុណភាពអង្ករឆ្នាំ២០១៦កន្លងទៅមិនបានជាប់ចំណាត់ថ្នាក់លេខ១ទេ តែអង្ករកម្ពុជាបានជាប់ចំណាត់ថ្នាក់កំពូលទាំង៣ ហើយនៅតែជាគូប្រកួតប្រជែងដ៏ស្វិតស្វាញនិងមានសក្តានុពលបំផុតជាមួយអង្ករជ័យលាភីរបស់ថៃ ដោយសារអង្ករកម្ពុជាធ្លាប់ទទួលបានកិត្តិយសឈ្នះពានរង្វាន់អង្ករល្អបំផុតរហូតដល់ទៅ៣ឆ្នាំជាប់ៗគ្នា។

យោងតាមការអះអាងរបស់ លោក Jeremy Zwinger ប្រធានប្រតិបត្តិនៃ The Rice Trader ជាក្រុមហ៊ុនរៀបចំសន្និសីទនេះ សម្រាប់ការជ្រើសរើសអង្ករថៃជាប់លេខ១ក្នុងឆ្នាំនេះគឺជារឿងលំបាកក្នុងការសម្រេចចិត្តរបស់ចុងភៅ ដែលត្រូវបានគេអញ្ជើញដើម្បីដឹកនាំការជ្រើសរើសនេះក្នុងសន្និសីទស្រូវអង្ករអន្តរជាតិ (The World Rice Conference) កាលពីថ្ងៃទី១៨ខែវិច្ឆិកាឆ្នាំ២០១៦។ អង្ករកម្ពុជាស្ថិតក្នុងចំណោមការជ្រើសរើសចម្រាញ់យ៉ាងលំបាក ហើយ បានទម្លាក់សំណាកអង្ករចំនួន២០ផ្សេងទៀត មកពីប្រទេសសរុប១៤ ដែលបានដាក់ប្រកួតប្រជែង។តាមអ្នករៀបចំការប្រកួត សំណាកអង្ករភាគច្រើន ដាក់ដោយប្រទេសថៃ និង ប្រទេសមីយ៉ាន់ម៉ា។ លោក Jeremy Zwinger បានប្រកាសថាអង្ករកម្ពុជាស្ថិតក្នុងចំណោម អង្ករល្អបំផុតនេះ ខណៈអង្ករពីប្រទេសវៀតណាម មីយ៉ាន់ម៉ា និង ប្រទេសជាច្រើនទៀត មិនបានជាប់នោះទេ សូម្បីអង្ករ ប៉ាស្មាទី ដែលគេដាំដុះភាគច្រើននៅប្រទេសឥណ្ឌា ប៉ាគីស្ថាន ដែលជាប្រទេសនាំចេញ អង្ករយ៉ាងច្រើនទៅកាន់ទីផ្សារចិន និងទីផ្សារនៅមជ្ឈឹមបូព៌ា។ **ឯកឧត្តម សុខ ពុទ្ធីវុធ** ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា បានយល់ថា សណ្ឋានដី ទីតាំងភូមិសាស្ត្រ នៃប្រទេសកម្ពុជានិងថៃគឺប្រហាក់ប្រហែលគ្នា ដូចនេះ គុណភាពអង្ករនៃប្រទេសទាំងពីរមិនខុសគ្នានោះទេ។ ឯកឧត្តម បានលើកឡើងថា អ្វីដែលកម្ពុជាត្រូវគិតគូរគឺត្រូវគិតពីផែនការឲ្យច្បាស់លាស់ ខណៈបញ្ហាទីផ្សារនិងតម្លៃរបស់កម្ពុជានៅមិនទាន់ដោះស្រាយបាន។ កម្ពុជាធ្លាប់ឈ្នះពានអង្ករល្អបំផុតដំបូងបំផុតនៅឆ្នាំ ២០១២ ដែលគេរៀបចំឡើងនៅកោះបាលី ប្រទេសឥណ្ឌូនេស៊ី ហើយ ពីរឆ្នាំបន្តបន្ទាប់គឺ ឆ្នាំ២០១៣ នៅទីក្រុងហុងកុង និង ឆ្នាំ២០១៤ ជាពេលដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះនៃ (The World Rice Conference) នៅក្នុងខែវិច្ឆិកាដូចគ្នានេះ។





## ពិព័រណ៌ និង ការផ្លាស់ប្តូរពាណិជ្ជកម្ម

# វត្តមានអង្ករឆ្ងាញ់បំផុតក្នុងពិភពលោកកំពុងមានវត្តមាន ពិព័រណ៌ម្ហូបអាហារ នៅអាស៊ីនៅប្រទេសថៃ

សហព័ន្ធស្រូវអង្ករកម្ពុជា (CRF) រួមជាមួយក្រុមហ៊ុនជាសមាជិករបស់សហព័ន្ធប្រាំផ្សេងទៀត កំពុងមានវត្តមានក្នុងពិព័រណ៍ម្ហូបអាហារប្រចាំតំបន់អាស៊ី ហៅកាត់ថា THAIFEX នៅក្នុងប្រទេសថៃ ដើម្បីតាំងបង្ហាញផលិតផលអង្ករថ្មីៗដែលក្រុមហ៊ុនជាសមាជិកខិតខំប្រឹងប្រែងផលិតនិងអភិវឌ្ឍចុងក្រោយ ដល់អ្នកចូលរួមមកពីជុំវិញពិភពលោក។

សហព័ន្ធស្រូវអង្ករកម្ពុជា ដោយមានការសហការពីសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ(IFC) បានសម្រេចចិត្តចូលរួមពិព័រណ៍មួយនេះដើម្បីបង្ហាញផលិតផល និង ផ្តល់ព័ត៌មានថ្មីៗដល់អ្នកបញ្ជាទិញនិងភ្ញៀវអន្តរជាតិ ពាក់ព័ន្ធវិស័យស្រូវអង្ករ ដែលជាអង្ករទទួលបាននូវពានរង្វាន់ជាអង្ករល្អបំផុតក្នុងពិភពលោក បីឆ្នាំជាប់ៗគ្នា គឺ ឆ្នាំ២០១២ ២០១៣ និង ឆ្នាំ២០១៤។

ក្រុមហ៊ុនកម្ពុជាទាំងប្រាំ ដែលបានចូលរួមបង្ហាញផលិតផលរបស់ខ្លួននៅពីព័រណ៍ថ្នាក់តំបន់THAIFEX រួមមានៈ

- ក្រុមហ៊ុន ខ្មែរហ្វូត (Khmer Foods Group Co., Ltd.)
- ក្រុមហ៊ុន ហ្គោលដិនរ៉ាយ Golden Rice (Cambodia) Co.,Ltd
- ក្រុមហ៊ុន ស៊ីធីរ៉ាយ City Rice Import Export Co.,Ltd
- ក្រុមហ៊ុន អប្សរារ៉ាយ (Apsara Rice (Cambodia) Co.,Ltd
- ក្រុមហ៊ុន Mekong Agro (KH) Industries Limited

ស្តង់តាំងពិព័រណ៍កម្ពុជា ស្ថិតក្នុងចំណោមស្តង់ពិព័រណ៍សរុប ១៩១៩ មកពីប្រទេសចំនួន៤០នៅក្នុងពិភពលោក។ ស្តង់ផលិតផលរបស់កម្ពុជាត្រូវបានរចនាឡើងដោយបង្ហាញនូវអត្តសញ្ញាណជាតិ ដោយយកប្រាសាទអង្គរវត្តជានិមិត្តសញ្ញា ព្រមទាំងមានសកម្មភាពនានាពាក់ព័ន្ធវិស័យកសិកម្មនៅក្នុងស្រុកជាពិសេសរបៀបដាំដុះរបស់ប្រជាកសិករខ្មែរ។

ក្នុងឱកាសនៃការបារព្ធវេទិកាស្រូវអង្ករនៅកម្ពុជាកាលពីខែមករាឆ្នាំ២០១៦ ប្រមុខរាជរដ្ឋាភិបាលកម្ពុជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ធ្លាប់បានកោតសរសើរប្រកបដោយមោទនភាពចំពោះកសិករកម្ពុជាថា ជាអ្នកដែលបានខិតខំ ប្រឹងប្រែងតស៊ូព្យាយាម និង សង្វាត ក្នុងការងារបង្កបង្កើនផលស្រូវ ហើយផលិតបានអង្ករដ៏ឆ្ងាញ់សម្រាប់ពិភពលោក។






សកម្មភាពតាំងពិព័រណ៍នៅ THAIFEX

## ការសិក្សាបង្កើត «តែម» សម្រាប់អង្ករក្នុងស្រុក

# សហព័ន្ធស្រូវអង្ករកម្ពុជា ផ្តួចផ្តើមបង្កើត «តែម» សំគាល់ផលិតផលអង្ករខ្មែរ

វិស័យស្រូវអង្ករនៅកម្ពុជាត្រូវតែមានរបៀបរៀបរយ។ របៀបរៀបរយ អាចធានាបាននូវគុណភាពអង្ករខ្មែរពិតប្រាកដ ធានាបាននូវការគ្រប់គ្រងជាក់លាក់ និង បញ្ចៀសបាននូវបាតុភាពទាំងឡាយ ដូចជាករណីការលាយអង្ករនាំចូល ការផលិតអង្ករប្លាស្ទិក ការលក់អង្ករប្រើប្រាស់សារធាតុគីមីច្រើន និង បញ្ហាជាច្រើនទៀត ដែលគេតែងបានដឹង និង បានឮក្នុងពេលកន្លងមក។ ដើម្បីបញ្ចៀសបញ្ហាស្មុគស្មាញ ដែលរកឫសគល់ដោយលំបាក និង ដែលតែងប៉ះពាល់ដល់វិស័យស្រូវអង្ករជារឿយៗ សហព័ន្ធស្រូវអង្ករកម្ពុជា បានផ្តួចផ្តើមគំនិតបង្កើត «តែម» សម្រាប់សំគាល់និងបញ្ជាក់ផលិតផលអង្ករកម្ពុជាសុទ្ធ១០០% (ទោះបីការសម្រេចជាផ្លូវការមិនទាន់ធ្វើក្តី) តែគំនិតនេះត្រូវបានស្ថាប័ននានា បានផ្តល់ការគាំទ្រយ៉ាងខ្លាំង និង ជំរុញឲ្យបានចេញឆាប់ៗក្នុងពេលខាងមុខនេះ។ កន្លងមកនេះសហព័ន្ធស្រូវអង្ករកម្ពុជា បានបំពេញការងារយ៉ាងច្រើនក្នុងការស្វែងរកការគាំទ្រពីស្ថាប័នពាក់ព័ន្ធ សមាជិករបស់សហព័ន្ធ ដេប៉ូលក់អង្ករក្នុងក្រុងភ្នំពេញនិងតាមបណ្តាខេត្ត ព្រមទាំងបានចុះផ្ទាល់ជួបជាមួយសហគមន៍កសិកម្មជាច្រើនទៀតផង ដើម្បីចង់ដឹងថាតើ គំនិតនេះសមស្របតាមអ្វីដែលគាត់ចង់បាន និង ដើម្បីលុបបំបាត់ក្តីបារម្ភនានា។ លើសពីនេះទៅទៀតសហព័ន្ធបានបង្កើនកម្មវិធីផ្សព្វផ្សាយអំពីការគាំទ្រផលិតផលខ្មែរជួយកសិករកម្ពុជាដោយផ្សព្វផ្សាយយ៉ាងទូលំទូលាយតាមទូរទស្សន៍កាសែតនិងបណ្តាញសង្គមយ៉ាងច្រើនច្រើន។ ការងារផ្សព្វផ្សាយទាំងនេះ ដើម្បីជួយសម្រួលទីផ្សារដល់សមាជិកសហព័ន្ធស្រូវអង្ករកម្ពុជាទាំងមូល ដែលរួមមានទាំងសហគមន៍កសិករ ដេប៉ូចែកចាយលក់ដុំនិងលក់រាយ រោងម៉ាស៊ីន និង ក្រុមហ៊ុននាំចេញទាំងអស់ និង ការធានាបាននូវគុណភាពអង្កររបស់កម្ពុជាឲ្យទៅដល់សាធារណៈជនដោយពិតប្រាកដ។

ការងារទាំងនេះក៏ផ្អែកតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់បំផុត របស់សម្តេចតេជោ នាយករដ្ឋមន្ត្រី ដែលបានអំពាវនាវដល់សាធារណៈជននិងភាគីពាក់ព័ន្ធទាំងស្ថាប័នរដ្ឋនិងឯកជនចូលរួមទិញអង្ករកម្ពុជា។

សហព័ន្ធស្រូវអង្ករកម្ពុជាទទួលស្គាល់ដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ២២៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែសីហាឆ្នាំ២០១៤។

### ខាងក្រោមនេះ គឺជាព័ត៌មានទូទៅនៃការបង្កើតតែមរបស់សហព័ន្ធស្រូវអង្ករកម្ពុជាៈ









## ការពង្រឹងការទប់ស្កាត់ពីប្រទេសជិតខាង

# ក្រសួងពាណិជ្ជកម្មទទួលយកសំណើរបស់សហព័ន្ធជុំវិញការនាំចូលអង្ករពីប្រទេសជិតខាង



ជំនួបពិភាក្សារវាង **ឯកឧត្តម សុខ ពុទ្ធិវុធ** និង **ឯកឧត្តម ប៉ាន សូរស័ក្តិ**

សំណើររបស់សហព័ន្ធស្រូវអង្ករកម្ពុជា៖«រាល់ការអនុញ្ញាតឲ្យនាំចូលអង្ករនិងការដាក់លក់លើទីផ្សារ ត្រូវមានព័ត៌មានអំពីអាសយដ្ឋាន ម៉ាកយីហោ និង ប្រភពច្បាស់លាស់ ដើម្បីពង្រឹងការនាំចូលអង្ករនិងគុណភាព អង្ករ ដែលបានចរាចរនៅលើទីផ្សារ» ត្រូវបានថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្ម ទទួលយកនិងត្រៀមអនុវត្តឲ្យមានប្រសិទ្ធភាព។

សំណើរនេះត្រូវបានលើកយកទៅពិភាក្សាចំនួនពីរលើករួចមកហើយ គឺលើកទី១៖ កិច្ចប្រជុំពិសេសរវាងថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្មដឹកនាំដោយ **ឯកឧត្តម ប៉ាន សូរស័ក្តិ** និង ថ្នាក់ដឹកនាំសហព័ន្ធស្រូវអង្ករកម្ពុជាដឹកនាំដោយ **ឯកឧត្តម សុខ ពុទ្ធិវុធ** នៅថ្ងៃទី១២ ខែសីហាឆ្នាំ២០១៦ និងលើកទី២៖ កិច្ចប្រជុំក្រុមការងារចំរុះរវាងក្រសួងពាណិជ្ជកម្ម និង សហព័ន្ធស្រូវអង្ករកម្ពុជា កាលពីថ្ងៃទី១៥ខែសីហាឆ្នាំ២០១៦ នៅទីស្តីការក្រសួងពាណិជ្ជកម្ម ថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្មបានគាំទ្រចំពោះសំណើររបស់សហព័ន្ធស្រូវអង្ករកម្ពុជា ដែលស្នើឲ្យក្រសួងពាណិជ្ជកម្មតាមរយៈកាំកុងត្រូល ត្រូវត្រួតពិនិត្យអង្ករឲ្យបានច្បាស់លាស់មុនអនុញ្ញាតឲ្យនាំចូល។នៅក្នុងកិច្ចប្រជុំនោះថ្នាក់ដឹកនាំក្រសួងពាណិពជ្ជកម្ម បានយល់ព្រមរិតបន្តឹងការនាំចូលអង្ករពីប្រទេសជិតខាង ដោយក្រសួងនឹងចេញជាលិខិតជាលាយលាក់អក្សរទៅកាន់ស្ថាបន័អនុវត្តច្បាប់ ជាពិសេសគឺកាំកុងត្រូល និងក្រុមហ៊ុននាំចូលទាំងអស់ឲ្យអនុវត្តទៅតាមច្បាប់របស់ក្រសួងពាណិជ្ជកម្ម ស្តីអំពីការនាំចូលដែលតាមសំណើររបស់សហព័ន្ធ ហើយច្បាប់នេះបានកំណត់ថាការនាំចូលត្រូវតែមានសម្រករវេចខ្ចប់ត្រឹមត្រូវ មានម៉ាកសញ្ញាក្រុមហ៊ុន និង អាសយដ្ឋានផលិតច្បាស់លាស់ក្នុងការចរាចរលក់តាមទីផ្សារ។

**លោក មូល សារិទ្ធិ** អគ្គលេខាធិការសហព័ន្ធស្រូវអង្ករកម្ពុជា បានលើកឡើងដោយក្តីរីករាយថា ការយល់ព្រមរបស់ក្រសួងពាណិជ្ជកម្មចំពោះសំណើរនោះ គឺជារឿងល្អមួយ ដែលនឹងផ្តល់ឱកាសឲ្យវិស័យកសិកម្មជាពិសេសស្រូវអង្ករមានលទ្ធភាពលូតលាស់ឡើងវិញ និង ពង្រឹងគុណភាពផលិតផលជាតិ។

លោក អះអាងថា ក្រោយពីមានការដាក់លិខិតចំនួនពីរលើកទៅកាន់ក្រសួងពាណិជ្ជកម្ម ដោយស្នើសុំក្រសួងចេញនូវបទបញ្ញត្តិផ្សេងៗ ឬក៏ពង្រឹងទៅលើអង្ករនាំចូល ដោយធ្វើយ៉ាងណា ឲ្យអង្ករនាំចូលទាំងនោះមានប្រភពព័ត៌មានច្បាស់លាស់ ដូចជាសំបកវេចខ្ចប់មានម៉ាកសញ្ញាជាក់លាក់ មានអាសយដ្ឋានពិតប្រាកដ ដោយមិនត្រឹមតែការនាំចូលនោះទេ សូម្បីការចរាចរនៅលើទីផ្សារក៏ត្រូវធានានូវភាពត្រឹមត្រូវ។

លោក អះអាងថា កន្លងមកក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ ក៏ធ្លាប់បានបង្ហាញនូវការគាំទ្រចំពោះវិធានការដំឡើងពន្ធនាំចូល។

លោក បន្ថែមថា កន្លងមកសមាជិករបស់សហព័ន្ធ ក៏ធ្លាប់មានការត្អូញត្អែរថា មានអ្នកនាំចូលខ្លះយកម៉ាកយីហោ ឬបាវវេចខ្ចប់របស់រោងម៉ាស៊ីនគាត់ទៅដាក់ផលិតផលនាំចូល រួចលក់តាមទីផ្សារ តែអង្ករនោះមិនមែនជាអង្កររបស់រោងម៉ាស៊ីននោះទេ។

លោក បានអះអាងទៀតថា សហព័ន្ធស្រូវអង្ករកម្ពុជាក៏មានគណៈកម្មាធិការមួយក្នុងចំណោមគណៈកម្មាធិការទាំង៦ នោះគឺគណៈកម្មាធិការវិន័យនិងក្រមសីលធម៌ សម្រាប់តាមដានការអនុវត្តការងារនេះ ហើយសហព័ន្ធកំពុងតែសហការជាមួយក្រុមហ៊ុនអធិការកិច្ចផ្សេងៗ ដើម្បីស្វែងរកលទ្ធភាពចុះត្រួតពិនិត្យតាមរោងម៉ាស៊ីន ឬ ក៏ដេប៉ូចែកចាយអង្ករ ដើម្បីធានាថា អង្ករទាំងនោះ លក់ស្របច្បាប់របស់កម្ពុជាដោយមានអាសយដ្ឋានពិតប្រាកដ និង ម៉ាកសញ្ញាត្រឹមត្រូវ៕


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King
ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

ប្រកាស
ស្តីពី
នីតិវិធីនៃការនាំចូលអង្ករពីបរទេស
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម




ប៉ាន សូរស័ក្តិ





## ដំណើរការបង្កើតនិងចុះបញ្ជីម៉ាកវិញ្ញាបនកម្ម (certification Mark)

## ក្រសួងពាណិជ្ជកម្ម ពង្រឹងនីតិវិធីនៃការនាំចូលអង្ករពីបរទេស

ក្រោយមានកិច្ចប្រជុំជាបន្តបន្ទាប់ដែលស្នើឡើងដោយសហព័ន្ធស្រូវអង្ករកម្ពុជាក្នុងការដោះស្រាយភាពមិនប្រក្រតីនៃការនាំចូលអង្ករពីបរទេសជាពិសេសប្រទេសវៀតណាម ដើម្បីលាយជាមួយអង្ករក្នុងស្រុក ឬលក់ចែកចាយដោយបន្លំឈ្មោះរបស់រោងម៉ាស៊ីនក្នុងស្រុក ឯកឧត្តម ប៉ាន សូរស័ក្តិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានចេញប្រកាសចុះថ្ងៃទី០៩ខែកញ្ញាឆ្នាំ២០១៦ តម្រូវឲ្យក្រុមហ៊ុនឬអ្នកនាំចូលអង្ករអនុវត្តតាម ដើម្បីរក្សាបាននូវការធ្វើពាណិជ្ជកម្មដោយសមធម៌ និង អនុលោមភាពជាមួយវិធានប្រភពដើមទំនិញ។

ប្រកាសថ្មីនេះកើតឡើង បន្ទាប់ពីថ្នាក់ដឹកនាំសហព័ន្ធស្រូវអង្ករកម្ពុជា បានលើកពីបញ្ហាកង្វល់នានាពាក់ព័ន្ធការនាំចូលអង្ករពីប្រទេសជិតខាងដោយគ្មានភាពច្បាស់លាស់ ដែលនាំដល់ការបង្កផលលំបាកដល់ផលិតកម្មក្នុងស្រុក និង ក្រោយពីមានកិច្ចប្រជុំយ៉ាងហោចណាស់ពីរលើកកាលពីខែសីហាឆ្នាំ២០១៦ ជាមួយថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្ម ដើម្បីស្នើឲ្យក្រសួងមានចំណាត់ការចំការនាំចូលអង្ករពីបរទេសដោយគ្មាប្រភពច្បាស់លាស់។

ប្រកាសថ្មីៗបំផុតរបស់ក្រសួងពាណិជ្ជកម្មពាក់ព័ន្ធជំនួញនាំចូលអង្ករនេះ គឺជាអ្វីដែលសហព័ន្ធស្រូវអង្ករកម្ពុជាជាពិសេសសមាជិករបស់ខ្លួនចង់បាន ចង់ឃើញ និងអនុវត្តឲ្យបានតឹងរឹង ដើម្បីឲ្យការប្រកួតប្រជែងមានតម្លាភាពក្នុងទីផ្សារសេរី។

ប្រកាសថ្មីរបស់ក្រសួងពាណិជ្ជកម្មត្រង់ប្រការ១ បានចែងថា៖«ត្រូវបានដាក់ឲ្យអនុវត្តនូវការបំពេញបែបបទស្នើសុំនាំចូលអង្ករពីបរទេស ក្នុងគោលបំណងរក្សាបាននូវការធ្វើពាណិជ្ជកម្មដោយសមធម៌ និង អនុលោមភាពជាមួយវិធានប្រភពដើមទំនិញ»។

**ត្រង់ប្រការ២** ក្រសួងពាណិជ្ជកម្មបានតម្រូវឲ្យក្រុមហ៊ុន ឬអ្នកនាំចូលអង្ករ ត្រូវដាក់ពាក្យស្នើសុំមកក្រសួងពាណិជ្ជកម្ម ដោយបំពេញបែបបទនិងភ្ជាប់ឯកសារ ដូចខាងក្រោម៖

- ពាក្យស្នើសុំ
- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ឬ អាជីវកម្ម ចំពោះករណីស្នើសុំលើកដំបូង
- វិក្កយបត្រ និង តារាងវេចខ្ចប់
- កិច្ចសន្យាទិញលក់

**ត្រង់ប្រការ៣** ក្រសួងពាណិជ្ជកម្ម បានប្រកាសថា រាល់ការនាំចូលអង្ករពីបរទេស ចាំបាច់ត្រូវមានភាពអនុលោមតាមលក្ខខណ្ឌតម្រូវនៃបទដ្ឋានច្បាប់។ ក្រុមហ៊ុន ឬអ្នកនាំចូលអង្ករពីបរទេស ត្រូវមានសំបកវេចខ្ចប់សមស្រប និង ត្រូវបោះពុម្ពនូវព័ត៌មានដូចខាងក្រោម៖

- ក្រុមហ៊ុននាំចូលនិងអាសយដ្ឋាន
- ក្រុមហ៊ុនផ្គត់ផ្គង់
- ទម្ងន់ (គិតជាគីឡូក្រាម)
- ប្រភព និង
- កាលបរិច្ឆេទផុតកំណត់នៃការប្រើប្រាស់

**ត្រង់ប្រការ៤** ក្រសួងពាណិជ្ជកម្ម បានលើកឡើងថា «ក្រោយពីទទួលបានពាក្យស្នើសុំ ក្រសួងពាណិជ្ជកម្មត្រូវផ្តល់ការយល់ព្រមឲ្យនាំចូលអង្ករក្នុងរយៈពេលមិនឲ្យលើសពី ០២(ពីរ)ថ្ងៃ នៃថ្ងៃធ្វើការ។ សុពលភាពនៃការយល់ព្រមឲ្យនាំចូលអង្ករត្រូវមានរយៈពេល ០៣ (បី) ខែ គិតចាប់ពីកាលបរិច្ឆេទនៃការអនុញ្ញាត។

**ប្រការ៥** ក្រសួងពាណិជ្ជកម្ម បានចែងថា «ក្នុងករណីមានបណ្តឹងតវ៉ា មន្ត្រីជំនាញក្រសួងពាណិជ្ជកម្ម ត្រូវសហការជាមួយអង្គភាព ពាក់ព័ន្ធដើម្បីចុះទៅធ្វើអធិការកិច្ច។ សហព័ន្ធស្រូវអង្ករកម្ពុជា អាចផ្តល់ព័ត៌មាននិងចូលរួមសង្កេតការណ៍តាមការចាំបាច់។

## ចូលរួមជាមួយក្រសួងកសិកម្មក្នុងគណៈកម្មាធិការតម្រង់ទិស លើគម្រោងជំរុញផលិតកម្មស្បៀង

ថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦នៅអគ្គនាយកដ្ឋានកសិកម្មកិច្ចប្រជុំនៃគណកម្មាធិការតម្រង់ទិសសម្រាប់គម្រោងផលិតកម្មស្បៀងត្រូវបានប្រព្រឹត្តឡើងក្រោមអធិបតីភាពឯកឧត្តម ទី សុគន្ធ រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាប្រធានគណៈកម្មាធិការតម្រង់ទិសនៃគម្រោង។ កិច្ចប្រជុំនេះមានសមាសភាពចូលរួម ពីតំណាងក្រសូងកសិកម្ម ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងសហព័ន្ធស្រូវអង្ករកម្ពុជា។

ក្នុងគណៈកម្មាធិការតម្រង់ទិសនេះ **ឯកឧត្តម សុខ ពុទ្ធីវុធ** ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា ក៏ជាសមាជិកម្នាក់ នៅកកនុងនោះដែរ។គម្រោងជម្រុញផលិតកម្មស្បៀង ជាគម្រោងដែលឧបត្ថម្ភថវិកាដោយរាជរដ្ឋាភិបាលកម្ពុជាផ្ទាល់ ចំនួន២០លានដុល្លារអាមេរិកលើគម្រោងបង្កើនផលិតកម្មស្រូវក្រអូប និងផលិតកម្មបន្លែ។

គម្រោងនេះមានរយៈពេល៣ឆ្នាំ ២០១៦-២០១៨ សំដៅបង្កើនពូជស្រូវក្រអូបសរុបអោយបាន ១៥០០០ តោន នៅក្នុងរយៈពេល៣ឆ្នាំ នៅខេត្តចំនួន១១ និងបង្កើនការផលិតបន្លែសរុបអោយបាន ៦ម៉ឺនតោនក្នុងមួយឆ្នាំ នៅខេត្ត ចំនួន៨ ដើម្បីជម្រុញផលិតកម្មស្បៀង ឆ្លើយតបតម្រូវការស្បៀងនៅក្នុងទីផ្សារ។ គម្រោងនឹងធ្វើការជាមួយសហគមកសិកម្ម រោងម៉ាស៊ីន អ្នកផលិតពូជ និងភាគីពាក់ព័ន្ធដទៃទៀតនៅតាមបណ្តាខេត្តនានា។ កិច្ចប្រជុំបានផ្លាស់ប្តូរយោបល់គ្នា អំពីគំនិតផ្សេងៗ ពីយន្តការនានា សំដៅធ្វើយ៉ាងណា អោយគម្រោងនេះសម្រេចបានតាមគោលដៅ និងប្រកបដោយប្រសិទ្ធភាពខ្ពស់។




ដំណើរការកិច្ចប្រជុំលើកដំបូងរបស់ក្រុមការងារគម្រោងជំរុញផលិតកម្មស្បៀងនៅអគ្គនាយកដ្ឋានកសិកម្ម

# Model Farmland focus

*Japanese Institute of Irrigation and Drainage (JIID) contributes Cambodian rice production through developing model farmland and providing farmers training in Battambang province in Cambodia*

On 28th of February 2016, about 140 ha of model farmland in the part of Kamping Pouy irrigation system located in O'Ta nhea village, Ta Kream Commune Banon District Battanbang province supported by Japanese Institute of Irrigation and Drainage (JIID) was completed.

This project was implemented by JIID under the study on promotion of agricultural infrastructure development project funded by the Japanese government. The objective of the study is to promote agricultural infrastructure development through strengthening the food value chain accompanying remarkable economic growth in Cambodia.

tural development on both policy and technical matters in and out of Japan, mainly in Asia. Since 2000, JIID has shared its experiences on irrigation and drainage through conducting several joint studies with the Ministry of Water Resource and Meteorology (MOWRAM) of Cambodia. For example, recent works are how to promote participatory irrigation management and strengthen farmers' water users' groups, and how to prevent rural areas from disastrous damages through the establishment of an early warning system and implementation of an evacuation drill, etc.

There are 97 beneficial households in model farmland in Battanbang. And farmers cultivates paddy in twice in a year. Four tertiary canals with total length of 2,530m were rehabilitated and farm roads were development paved by laterite along with the each canal. Furthermore four intake structures were rehabilitated and five offtake structures were newly constructed.

JIID and MOWRAM agreed the project site of the model farmland in 2014. There were several reasons why Komping Puoy area was selected as a model site. Firstly, the Battanbang province was one of the leading provinces on rice production, secondly, irrigated water was available, and thirdly farm plot size was large enough to use farming machineries.

Before the start of the project, the officers of the Battanbang provincial department of Water Resource and Meteorology (PDOWRAM) explained farmers to construct the canals and farm roads in the model farmland through farmers' water users' groups. The advantage of farm roads was explained to all farmers whose farmland was along the farm roads.

The survey and design of the model farmland were implemented by the PDOWRAM of Battanbang. The construction work was implemented by a private contractor. The PDOWRAM supervised the construction. The construction period was only two months (1st January to 28th February, 2016)

Besides the development of the model farmland, three training programs were provided to the related farmers. First was strengthening farmers' water users' groups in the model farmland conducted by the PDOWRAM in 2015. Second was a training of the usage and maintenance of power tillers, tractors, and combined harvesters with Battanbang provincial department of agriculture in 2016. Third was the training of farming technique through famer's field school provided by the Ministry of Agriculture and Forestry and Fisheries of Cambodia in 2016.

According to the interviews to the farmers after the project, farmers began to use irrigation water individually and independently by adding field ditch. Irrigation water could reach each plot in the farmland timely. The access to respective farm plots became easier. Some farmers said they wanted to manage bigger farm size plots and use more agricultural machineries. The participation of beneficial farmers to the operation and maintenance of the irrigation system was improved through the training to them. The yields of the paddy fields have improved. JIID is now conducting the surveys of farmers' actual farming activities, yields, farming costs, the usage of the machineries etc. Near future, JIID would like to have an opportunity to report the output of the study in Cambodia.



The location of model farmland 1



The location of model farmland 2



The completion of model farmland construction



JIID staffs and beneficial farmers after completion



Canal　　Farm Road　　Plain figure of model farmland

## ក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ

## ក្រសួងសេដ្ឋកិច្ចបញ្ចុះថ្លៃម៉ាស៊ីនស្កេនដល់ទំនិញអង្ករនាំចេញរយៈពេលពីរឆ្នាំ២០១៧-២០១៨

ឯកឧត្តម ទេសរដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានចេញលិខិតមួយ ចុះថ្ងៃទី០៦ខែតុលាឆ្នាំ២០១៦ ជំរាបជូន ឯកឧត្តម អគ្គនាយកនៃអគ្គនាយកគយនិងរដ្ឋាករកម្ពុជា អំពីការកែសម្រួលជាបណ្តោះអាសន្ននូវកម្រៃត្រួតពិនិត្យតាមប្រព័ន្ធម៉ាស៊ីនស្កេន លើមុខទំនិញអង្ករនាំចេញ ដឹកជញ្ជូនក្នុងកុងតែន័រ។

ការកែសម្រួលយកថ្លៃនេះ ផ្អែកតាមចំណារដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី២០ខែកញ្ញាឆ្នាំ២០១៦ លើលិខិតរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ការកែសម្រួលនឹងមានសុពលភាពរយៈពេលពីរឆ្នាំ ចាប់ពីថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ២០១៦រហូតដល់ថ្ងៃទី៣១ ខែធ្នូឆ្នាំ២០១៨។ ផុតកំណត់ពេលនេះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងធ្វើការកែសម្រួលជាថ្មីនូវកម្រៃត្រួតពិនិត្យតាមប្រព័ន្ធម៉ាស៊ីនស្កេន លើមុខទំនិញអង្ករនាំចេញ។

លោក **មូល សារិទ្ធី** អគ្គលេខាធិការ សហព័ន្ធស្រូវអង្ករកម្ពុជា បានថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលដែលតែងតែយកចិត្តទុកដាក់ជួយដល់វិស័យស្រូវអង្ករ ទោះបីការបញ្ចុះថ្លៃនេះហាក់នៅតូច តែវាបានរួមចំណែកដល់ការកាត់បន្ថយថ្លៃដើម ដែលវិស័យឯកជនតែងតែចង់បានដើម្បីបង្កើនសមត្ថភាពប្រកួតប្រជែងជាមួយអង្ករនៃប្រទេសជិតខាង។

ការបញ្ចុះតម្លៃលើសេវាស្កេនអង្ករស្មើប្រមាណ៥០ភាគរយ ដោយបញ្ចុះពីតម្លៃ២០ដុល្លារមកនៅត្រឹម១០ដុល្លារ សម្រាប់កុងតែន័រ២០ហ្វីត និងបញ្ចុះពី៣២ដុល្លារមកនៅត្រឹម១៦ដុល្លារសម្រាប់កុងតែន័រចាប់ពី៤០ហ្វីតឡើង។

លោក មូល សារិទ្ធី ក៏សូមសំណូមពរឲ្យគ្រប់ស្ថាប័នពាក់ព័ន្ធទាំងអស់ រួមគ្នាសិក្សាពីសង្វាក់ផលិតកម្មទាំងមូល ដើម្បីរកគន្លឹះកាត់បន្ថយថ្លៃដើមនេះឲ្យកាន់តែមានប្រសិទ្ធភាពសម្រាប់វិស័យស្រូវអង្ករ។

## សហប្រតិបត្តិការជាមួយ ធនាគារជាតិ នៃកម្ពុជា

ដើម្បីស្វែងយល់ដល់ការធ្វើហិរញ្ញប្បទានក្នុងវិស័យស្រូវអង្ករ សហព័ន្ធស្រូវអង្ករកម្ពុជា បានសហការជាមួយធនាគារជាតិក្នុងការធ្វើការសិក្សាស្រាវជាវ ដោយបានធ្វើអង្កេតជាមួយកសិករចំនួន៩៩គ្រួសារ រោងម៉ាស៊ីនចំនួន៥៣ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនិងធនាគារចំនួន៣០ លើស្ថានភាពការទទួលឥណទាន និងការផ្តល់ឥណទាន របស់កសិករ រោងម៉ាស៊ីន និងអ្នកនាំចេញ ក៏ដូចជាស្ថានភាពផ្តល់ឥណទានរបស់គ្រឹះស្ថានហិរញ្ញវត្ថុ នៅតាម៨ខេត្តក្រុង ។

តាមរយៈការធ្វើអង្កេតនេះ យើងបានរកឃើញនូវការប្រឈមមួយចំនួនដែលជាឧបសគ្គដល់ការទទួលឥណទាន និងបានលើកនូវការជម្រើសដោះស្រាយផ្នែកគោលនយោបាយមួយចំនួនផងដែរ ដើម្បីសម្រួលដល់ការទទួលឥណទានសម្រាប់វិស័យស្រូវអង្ករនៅពេលខាងមុខ។







## ស្ថាប័នពាក់ព័ន្ធនានាគាំទ្រការបែងចែកតំបន់សម្រាប់ជំរុញផលិតកម្មស្រូវនិងប្រសិទ្ធភាពទំនាក់ទំនង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ: ១៤២ សជណ.កស

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០១៦

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**ជម្រាបជូន**
**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុ៖** ករណីរបាយការណ៍ស្តីពីលទ្ធផលនៃកិច្ចប្រជុំក្រុមការងារផ្នែកស្រូវ-អង្ករ នៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន។

**យោង៖** - លិខិតលេខ៧១៣៤ កសក ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៦ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ចំណារ **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៦។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនឯកឧត្តមជ្រាបថា រាជរដ្ឋាភិបាល បានឃើញនិងឯកភាពដូចខាងក្រោម៖

១-ឱ្យបង្កើតក្រុមការងារសម្របសម្រួលថ្នាក់តំបន់និងថ្នាក់ខេត្ត ដើម្បីជួយដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការងារស្រូវអង្ករនៅមូលដ្ឋាន ដោយក្រុមការងារនេះត្រូវដឹកនាំដោយឯកឧត្តមគណៈអភិបាលខេត្ត ឬអភិបាលរងខេត្ត និងមានការចូលរួមពីគ្រប់មន្ទីរពាក់ព័ន្ធនានានៅថ្នាក់ខេត្ត រួមនឹងសមាសភាពពីផ្នែកឯកជននៅថ្នាក់តំបន់និងថ្នាក់ខេត្ត។

២-ឱ្យបង្កើតប៉ុស្តិ៍ត្រួតពិនិត្យអនាម័យនិងភូតគាមអនាម័យនៅតាមច្រកនាំចេញនាំចូល ដើម្បីពិនិត្យឱ្យបានត្រឹមត្រូវលើផ្នែកអនាម័យនិងភូតគាមអនាម័យ ទប់ស្កាត់ការនាំចូលមកជាមួយអង្ករនូវមេរោគ សត្វល្អិត និងស្មៅចង្រៃ សំដៅធានាសុវត្ថិភាពស្បៀង និងសុខុមាលភាពសាធារណៈក្នុងប្រទេស។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងចាត់ចែងអនុវត្តតាមការគួរ។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**ប៊ុន-អ៊ុយ**

**ចម្លងជូន:**
-ក្រសួងមហាផ្ទៃ
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន
-ឯកសារ-កាលប្បវត្តិ

# កិច្ចប្រជុំក្រុមការងារទី៩ ផ្នែកស្រូវអង្ករ

ក្នុងឱកាសនៃកិច្ចប្រជុំក្រុមការងារទី៩ នៃវេទិការាជរដ្ឋាភិបាលនិងវិស័យឯកជន (ក្រុមការងារផ្នែកស្រូវ-អង្ករ) នៅព្រឹកថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៦ នេះ នាទីស្ដីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ **ឯកឧត្តម វេង សាខុន** រដ្ឋមន្ត្រីមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង ជាសហប្រធានក្រុមការងារទី៩ បានគាំទ្រឲ្យមានការរៀបចំរចនាសម្ព័ន្ធនៅថ្នាក់តំបន់ ដោយរួមបញ្ចូលខេត្តមួយចំនួនក្នុងតំបន់និមួយៗ ដើម្បីងាយស្រួលដល់កិច្ចសហប្រតិបត្តិនៅថ្នាក់ក្រោមជាតិរហូតដល់ថ្នាក់មូលដ្ឋាន។

នៅក្នុងកិច្ចប្រជុំក្រុមការងារដែលមានវត្តមានចូលរួមពីថ្នាក់ដឹកនាំក្រសួងនានា និងមន្ត្រីបច្ចេកទេសជាច្រើនរូប ដើម្បីពិភាក្សានិងស្វែងរកដំណោះស្រាយចំពោះបញ្ហាប្រឈមនានាក្នុងវិស័យស្រូវអង្ករ **ឯកឧត្តម វេង សាខុន** បានប្រកាសឯកភាព ចំពោះសំណើររបស់សហព័ន្ធស្រូវអង្ករកម្ពុជា ដែលគ្រោងបង្កើតរចនាសម្ព័ន្ធតាមខេត្ត ក្រោយពីតំណាងជាន់ខ្ពស់តាមបណ្ដាក្រសួងនានាបង្ហាញពីការគាំទ្រចំពោះសំណើររបស់សហព័ន្ធ។

ឯកឧត្តម រដ្ឋមន្ត្រី បានលើកឡើងថា ការរៀបចំក្រុមការងារតាមបណ្ដាខេត្ត ដែលមានឈ្មោះថា សហប្រធានតាមតំបន់និមួយៗ ដោយយកថ្នាក់ដឹកនាំជាអភិបាលខេត្ត ឬក៏អភិបាលរងខេត្ត ដើម្បីឲ្យមានសមត្ថភាពបញ្ជាធ្វើការងារនៅក្នុងខេត្ត ហើយ មន្ទីរនានាទាំងអស់នៅក្នុងខេត្តអាចសហការគ្នាល្អ។

ទន្ទឹមគ្នានឹងការប្រកាសឯកភាពឲ្យរៀបចំរចនាសម្ព័ន្ធតាមតំបន់ ឯកឧត្តមរដ្ឋមន្ត្រី បានជំរុញឲ្យសហព័ន្ធស្រូវអង្ករកម្ពុជារៀបចំផែនការឲ្យបានច្បាស់លាស់នៅតាមតំបន់ទាំងនោះ ហើយ តំបន់និមួយៗ មានខេត្តចំណុះប៉ុន្មាន? ហើយ ត្រូវជ្រើសរើសអភិបាលខេត្ត ឬអភិបាលរងខេត្តមួយសម្រាប់ធ្វើជាសហប្រធានក្នុងក្រុមការងារតាមតំបន់នោះដើម្បីជំរុញការងារនោះឲ្យដំណើរការល្អ។ ការងារនេះត្រូវជ្រើសរើសយកខេត្តណាមួយដែលនៅកណ្ដាលដើម្បីដាក់ទីតាំងលេខាធិការដ្ឋានដើម្បីពិភាក្សាការងារនេះ។

ឯកឧត្តម បានបន្តថា ការនាំចេញជាក់លាក់ដែលធានាដល់និរន្តភាពទីផ្សារ គឺត្រូវតែដឹងច្បាស់ពីការប្រើប្រាស់ពូជ ហើយធានាដល់ការដាំដុះ។ ការធានាដល់ការនាំចេញ គឺមិនអាចពឹងផ្អែកទៅលើតំបន់ណាដែលមានគ្រួសារកសិករមានដីស្រែកន្លះហិកតានោះទេ ពោលគឺត្រូវតែមានការវិនិយោគទ្រង់ទ្រាយធំ នៅតំបន់ណាមួយជាក់លាក់។

នៅក្នុងឱកាសនោះដែរ **ឯកឧត្តម សុខ ពុទ្ធិវុធ** ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា ក៏ដូចជាផ្នែកឯកជនទាំងអស់មានម្ចាស់រោងម៉ាស៊ីនកិនស្រូវតំណាងសហគមន៍កសិកម្ម បានសាទរចំពោះការគាំទ្ររបស់រាជរដ្ឋាភិបាលដែលមានឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្មជាសហប្រធានក្នុងក្រុមការងារទី៩នេះ។

ឯកឧត្តម បានបញ្ជាក់ថា«ក្នុងរយៈពេលវែងយើងគួរតែរៀបបែងចែកតួនាទីឲ្យបានច្បាស់នៅពេលខាងមុខ រវាងវិស័យឯកជនជាមួយរាជរដ្ឋាភិបាល ជាពិសេស ក្រសួងកសិកម្មនិងក្រសួងពាក់ព័ន្ធ»៕



កិច្ចប្រជុំក្រុមការងារទី៩ (ក្រុមការផ្នែកស្រូវ-អង្ករ) នៅទីក្រសួងកសិកម្ម កាលពីខែសីហា ឆ្នាំ២០១៦

- **លោក គុន អុស** មន្ត្រីសម្របសម្រួលតំបន់១ ដែលមានខេត្តតាកែវ កំពត់ កំពង់ស្ពឺ កោះកុង ព្រះសីហនុ និងខេត្តកែប ចុះជួបប្រជាកសិករ។



- **លោក ទិតសុទ្ធី ឌីយ៉ាណូរី** អ្នកសម្របសម្រួលតំបន់ ០៤ ដែលមានខេត្ត កំពង់ធំ សៀមរាប ឧត្តរមានជ័យ និង ព្រះវិហារ និងខេត្តកំពង់ចាម។ តំបន់០៤ ជាតំបន់មួយមានសក្ដានុពលខ្លាំងផងដែរ ដោយសារខេត្តស្ថិតក្នុងតំបន់មួយនេះមានទីតាំងភូមិសាស្ត្រល្អ ដោយនៅចន្លោះប្រភពទឹកមិនចេះរីងស្ងួតពីរ គឺ ទន្លេសាបនិង ទន្លេមេគង្គ។ ខេត្តស្ថិតនៅក្នុងតំបន់នេះជាពិសេសខេត្តសៀមរាបជាខេត្តគោលដៅនៃការពិសោធន៍ ពូជស្រូវធន់នឹងលក្ខខណ្ឌមិនអំណោយផលរបស់កសិករខ្នាតតូចនៅកម្ពុជា គឺពូជស្រូវ ខា១៥ និង ខា១៤។ ពូជស្រូវខា១៥ ជាពូជស្រូវស្រាលមិនប្រកាន់រដូវនិងមានសក្ដានុពលផ្ដល់ទិន្នផល ប្រមាណ៧៤០០ គ.ក្រ/ហិកតា ហើយរយៈពេលដាំដុះ ៩០-៩៥ ថ្ងៃ។ ពូជស្រូវនេះ ក៏ត្រូវបានរៀបចំពិសោធន៍នៅក្នុងខេត្តមួយចំនួនក្នុងតំបន់៤ផងដែរ។



- **លោក សាម ម្លិះ** អ្នកសម្របសម្រួលតំបន់ ០៥ ដែលកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ និងប៉ៃលិន។ លោក សាម ម្លិះ បានធ្វើរបាយការណ៍ជាប្រចាំពីតំបន់គោលដៅទាំងនោះនៅពេលដែលលោកចុះជួបសមាជិករបស់សហព័ន្ធ ក៏ដូចជាប្រជាសហគមន៍កសិករ។ យើងដឹងថា តំបន់០៥ដែលសហព័ន្ធស្រូវអង្ករ បានរៀបចំឡើងនេះមានសក្ដានុពលខ្លាំងក្នុងផលិតកម្មស្រូវអង្ករ ហើយ ក៏ជាប្រភពនាំចេញដ៏សំខាន់ផងដែរ។ ខាងក្រោមនេះជាកម្រងរូបភាពខ្លះដែលប្រធានគ្រប់គ្រង់តំបន់០៥ ចុះបំពេញការងារ។



**-សម្រាប់តំបន់០២ ដែលគ្របដណ្ដប់ ខេត្តគោលដៅចំនួន៤ខេត្ត កណ្ដាល ត្បូងឃ្មុំ ព្រៃវែង និងស្វាយរៀង និងតំបន់០៣ ដែលមានខេត្តគោលដៅចំនួន៤ខេត្ត ក្រចេះ ស្ទឹងត្រែង រតនគីរី និងមណ្ឌលគីរី សហព័ន្ធស្រូវអង្ករកម្ពុជាមិនទាន់មានបុគ្គលិកតំណាងតំបន់ទាំងនោះទេ។ រហូតមកដល់ពេលនេះ សហព័ន្ធស្រូវអង្ករកម្ពុជាកំពុងរៀបចំដំណើរការជ្រើសរើសបេក្ខនាពប្រចាំតំបន់នេះ។**

## សហការសម្របសម្រួលទទួលក្រុមហ៊ុនរដ្ឋចិន COFCO និង ការទស្សនកិច្ចនៅក្រុមហ៊ុន COFCO នៅទីក្រុងប៉េកាំងប្រទេសចិន

### ប្រតិបត្តិករក្នុងវិស័យស្រូវអង្ករពិភាក្សាគ្នារករូបមន្តអនុវត្ត MoU សម្រាប់ឆ្នាំ២០១៧ ដើម្បីនាំចេញអង្ករទៅកាន់ទីផ្សារចិន

ក្រោយពីដឹកនាំក្រុមការងារស្រូវអង្ករមាន ក្រុមហ៊ុននាំចេញជាដើមទៅទស្សនៈកិច្ចនៅប្រទេសចិនកាលពីពាក់កណ្តាល ខែធ្នូឆ្នាំ២០១៦សហព័ន្ធស្រូវអង្ករកម្ពុជា ក្រោមការសម្របសម្រួលរបស់គណៈកម្មាធិការជំរុញនិងផ្សព្វផ្សាយទីផ្សារជាមួយក្រុមហ៊ុននាំចេញដឹកនាំដោយឯកឧត្តម **សុខ ពុទ្ធីវុធ** ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា និង លោក **ចាន់ សុខទី** អគ្គនាយកក្រុមហ៊ុនរដ្ឋហ្គ្រីនត្រេដ បានរៀបចំកិច្ចពិភាក្សាពិសេសជាមួយម្ចាស់រោងម៉ាស៊ីន និង តំណាងក្រុមហ៊ុនដែលមានសិទ្ធិនាំចេញ ទៅកាន់ទីផ្សារចិន រករូបមន្តសម្រាប់អនុវត្ត អនុស្សរណៈយោគយល់គ្នាជាមួយភាគីចិនលើកូតា២០ម៉ឺនតោនក្នុងឆ្នាំ២០១៧។

កិច្ចប្រជុំបានប្រព្រឹត្តទៅក្រោមអធិបតីភាព ឯកឧត្តម សុខ ពុទ្ធីវុធ ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា និង លោក ចាន់ សុខទី អគ្គនាយកក្រុមហ៊ុនរដ្ឋហ្គ្រីនត្រេដ នៅថ្ងៃទី២២ខែធ្នូឆ្នាំ២០១៦ ព្រមទាំងម្ចាស់ក្រុមហ៊ុននិងតំណាងក្រុមហ៊ុនដែលទទួលបានការអនុញ្ញាតឲ្យនាំចេញទៅកាន់ទីផ្សារចិនសម្រាប់កូតាក្នុងឆ្នាំថ្មី។

កិច្ចប្រជុំបានផ្តោតសំខាន់លើរបៀបការនាំចេញទៅកាន់ទីផ្សារចិន ដោយជជែកពីរបៀបផ្សេងៗ ដើម្បីឲ្យការអនុវត្តមានភាពងាយស្រួល និង ទទួលបានការគាំទ្រក្នុងចំណោមអ្នកនាំចេញទាំងអស់ ខណៈដែលការអនុវត្តអនុស្សរណៈរវាងកម្ពុជានិងចិននឹងត្រូវអនុវត្តចាប់ពីដើមឆ្នាំ២០១៧ ខាងមុខដ៏ខ្លីនេះ រហូតដល់ដំណាច់ឆ្នាំ២០១៧។

នៅក្នុងឱកាសនោះ ឯកឧត្តម **សុខ ពុទ្ធីវុធ** ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា បានមានប្រសាសន៍ថា ការអនុវត្តអនុស្សរណៈនេះពិតជាមានសារៈសំខាន់ ដើម្បីឆ្លុះបញ្ចាំងពីសមត្ថភាពនាំចេញរបស់កម្ពុជា ទៅកាន់ទីផ្សារប្រទេសចិន ដែលទើបសម្រេចផ្តល់កូតាបន្ថែមរហូតទ្វេដង ព្រោះកន្លងមក ថ្វីត្បិតតែក្រុមហ៊ុននាំចេញរបស់កម្ពុជាមានច្រើន តែមានក្រុមហ៊ុនតិចតួចប៉ុណ្ណោះដែលបាននាំចេញទៅកាន់ទីផ្សារចិនពិតប្រាកដ។

ឯកឧត្តម បានបន្ថែមថា ក្នុងការអនុវត្តកូតាឆ្នាំ២០១៧ខាងមុខនេះ ក្រុមហ៊ុនចំនួន១៨ទទួកបានសិទ្ធិនាំចេញទៅកាន់ប្រទេសចិន តែជាបទពិសោធន៍ក្នុងពេលកន្លងមក មានតែក្រុមហ៊ុន៤ទៅ៥ប៉ុណ្ណោះដែលសកម្មក្នុងការនាំចេញទៅកាន់ទីផ្សារប្រទេសចិន។ ដោយឡែកក្រុមហ៊ុនដែលមិនត្រូវបានជ្រើសរើសសម្រាប់ការនាំចេញដោយផ្ទាល់ទៅកាន់ទីផ្សារចិន ហើយ ចង់រកច្រកនាំចេញទៅកាន់ទីផ្សារចិននោះ ក្រុមហ៊ុនទាំងនោះអាចចូលតាមច្រកសហព័ន្ធស្រូវអង្ករកម្ពុជា ដែលជាតួអង្គដ៏សំខាន់មួយសម្រាប់សម្របសម្រួលក្នុងការនាំចេញ។

កន្លងមកក្រុមហ៊ុនរដ្ឋចិន COFCO បានសម្រេចយកក្រុមហ៊ុននាំចេញ ចំនួន១៨សម្រាប់នាំចេញទៅកាន់ទីផ្សារចិនដោយផ្ទាល់ ខណៈដែលឈ្មោះក្រុមហ៊ុនច្រើនរហូតដល់ជិត៤០ ត្រូវបានបញ្ជូនឈ្មោះទៅភាគីចិនក្នុងពេលកន្លងមក។

ឯកឧត្តម សុខ ពុទ្ធីវុធ បានលើកឡើងថា៖ «ទីផ្សារមិនដែលនៅស្ងៀមនោះទេ ពេលខ្លះអ្នកទិញមានប្រៀបជាង ហើយពេលខ្លះទៀតអ្នកលក់ក៏មានប្រៀបខ្លាំងជាងដែរ»។

**ឧកញ៉ា ហ៊ុន ឡាក់** អនុប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា បានបារម្ភថា ការនាំចេញទៅកាន់ទីផ្សារចិននៅតែលំបាក ស្របពេលតម្លៃដើមផលិតអង្ករនៅកម្ពុជាមានរហូតដល់ ៤០៨ ទៅ៤១០ដុល្លារក្នុងមួយតោន តែ ក្រុមហ៊ុនរដ្ឋចិន COFCO ផ្តល់តម្លៃត្រឹមតែ៤០០ដុល្លារប៉ុណ្ណោះក្នុង១តោន។

ក្នុងត្រីមាសទី៤ឆ្នាំ២០១៦នោះដែរ មន្ត្រីនៃក្រសួងគ្រប់គ្រងត្រួតពិនិត្យ គុណភាព អធិការកិច្ច និងចត្តាឡីស័កសាធារណរដ្ឋប្រជាមានិតចិន (AQSIQ) បានចុះមកត្រួតពិនិត្យផ្ទាល់ចាប់តាំងពីថ្ងៃទី២៨ខែវិច្ឆិកាដល់ថ្ងៃទី១៣ក្នុងខែធ្នូនេះ ដើម្បីចុះត្រួតពិនិត្យលក្ខណៈសម្បត្តិរបស់ក្រុមហ៊ុននិងរោងម៉ាស៊ីនកិនស្រូវនៅកម្ពុជា។

កម្ពុជាតំណាងដោយឯកឧត្តម រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និង សមភាគីចិនតំណាងដោយប្រធានក្រុមហ៊ុនរដ្ឋចិន COFCO បានចុះអនុស្សរណៈយោគយល់គ្នាថ្មីមួយកាលពីថ្ងៃទី១៣ខែតុលាឆ្នាំ២០១៦ ដោយផ្តល់កូតានាំចេញអង្ករពីប្រទេសកម្ពុជាពី១០ម៉ឺនតោនទៅ២០ម៉ឺនតោន៕

ក្នុងការអនុវត្តអនុស្សរណៈយោគយល់គ្នានេះ ក្រុមហ៊ុនរដ្ឋចិន COFCO បានចុះហត្ថលេខាជាមួយក្រុមហ៊ុនរដ្ឋរបស់កម្ពុជា «ហ្គ្រីនត្រេដ» ដើម្បីនាំចេញទៅចិន ហើយ ក្រុមហ៊ុនហ្គ្រីនត្រេដត្រូវការធ្វើការងារជាមួយវិស័យឯកជន ដែលតំណាងដោយសហព័ន្ធស្រូវអង្ករកម្ពុជាក្នុងការប្រមូលទិញបរិមាណនាំចេញឆ្លើយតបតម្រូវការទីផ្សារ៕

## សហការជាមួយកាំកុងត្រូលក្នុងការត្រួតពិនិត្យអង្ករ (១-ចុះត្រួតពិនិត្យតាមដេប៉ូ ២-ការធ្វើតេស្តិ៍អង្ករ)

### ការងារចុះពិនិត្យសកម្មភាពលក់អង្ករតាមដេប៉ូនៅភ្នំពេញ

មន្ត្រីក្រសួងពាណិជ្ជកម្ម និង ថ្នាក់ដឹកនាំសហព័ន្ធស្រូវអង្ករកម្ពុជា បានចុះជួបផ្ទាល់ជាលើកដំបូងជាមួយម្ចាស់ដេប៉ូលក់អង្ករធំៗក្នុងរាជធានីភ្នំពេញចំនួន១៧ នៅថ្ងៃទី២៧ខែកញ្ញាឆ្នាំ២០១៦ ដោយមានវត្តមាន ឯកឧត្តម វ៉ា រុតសាន ទីប្រឹក្សាក្រសួងពាណិជ្ជកម្ម ប្រធានសាខាកាំកុងត្រូលចំនួន៣តំបន់ក្នុងនោះ មានប្រធានសាខាកាំកុងត្រូលរាជធានីភ្នំពេញ ខេត្តព្រៃវែង និង ខេត្តតាកែវ ព្រមទាំងក្រុមហ៊ុនត្រួតពិនិត្យគុណភាពចំនួន៣ចូលរួម ដើម្បីពិនិត្យពីសកម្មភាពលក់អង្ករនៅតាមដេប៉ូផ្ទាល់ ហើយ សហព័ន្ធស្រូវអង្ករកម្ពុជាក៏បានលើកឡើងពីការផ្តួចផ្តើមប្រើប្រាស់តែម សំគាល់«អង្ករកម្ពុជា១០០% ឬ Cambodian Local Rice Seal»។

ក្នុងឱកាសជួបជុំនិងសំណេះសំណាលលើកដំបូងនោះ **ឯកឧត្តម សុខ ពុទ្ធីវុធ** ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា បានជំរាបជូនអាជីវករទាំងអស់ដែលបានចូលរួមប្រជុំអំពីបំណងនៃការប្រើប្រាស់តែមសម្រាប់សម្គាល់ផលិតផលអង្ករកម្ពុជាដើម្បីជៀសវាងការក្លែងបន្លំ ម៉ាកអង្ករកម្ពុជា ពីសំណាក់ផលិតផលប្រទេសផ្សេង ព្រោះកន្លងមកមានបាតុភាពច្រើនពាក់ព័ន្ធការលាយអង្ករដែលនាំចូលគ្មានប្រភពច្បាស់លាស់។

យោងសេចក្តីប្រកាសរបស់សហព័ន្ធស្រូវអង្ករ កម្ពុជា នេះជាលើកដំបូងបំផុតក្នុងវិស័យស្រូវអង្ករកម្ពុជា ដែលសហព័ន្ធស្រូវអង្ករកម្ពុជាចាប់ផ្តើមផ្សព្វផ្សាយ នឹងដាក់ឲ្យអនុវត្តប្រើប្រាស់ «តែមសំគាល់ផលិតផលអង្ករខ្មែរសុទ្ធ ១០០% » ផ្លូវការនាពេលឆាប់ៗខាងមុខនេះ សម្រាប់បញ្ជាក់ពីភាពសុទ្ធ និង គុណភាពអង្ករ ក្នុងការលក់ចែកចាយទាំងទីផ្សារក្នុងស្រុកនិងអន្តរជាតិ បន្ទាប់ពីការគិតគូរ ដែលប្រើពេលជាយូរ ដើម្បីរកច្រកចេញសម្រាប់បង្កើតសេចក្តីទុកចិត្តលើ គុណភាព ប្រភពដើមទំនិញ ភាពសុទ្ធ នៃអង្កររបស់ខ្មែរ។

**ឯកឧត្តម វ៉ា រុតសាន** ទីប្រឹក្សាក្រសួងពាណិជ្ជកម្ម បានលើកឡើងថា ការដាក់ឲ្យប្រើប្រាស់ម៉ាកយីហោអង្ករខ្មែរដែលគ្រោងបង្កើតឡើងដោយសហព័ន្ធស្រូវអង្ករកម្ពុជា គឺជាកត្តាចាំបាច់មួយសម្រាប់នាំវិស័យស្រូវអង្ករស្ថាបនាបាននូវអត្តសញ្ញាណដើម្បីឲ្យមានការទទួលស្គាល់ពីទីផ្សារ។

នៅក្នុងពិធីសំណេះសំណាលលើកដំបូងនោះ អាជីវករលក់អង្ករបានសំដែងការគាំទ្រនូវគំនិតផ្តួចផ្តើមថ្មីនេះ ព្រោះវានឹងនាំឲ្យខ្មែរស្គាល់ផលិតផលរបស់ខ្លួនកាន់តែច្បាស់ ហើយ រួមគ្នាលើកស្ទួយ តាមរយៈការប្រើប្រាស់ប្រកបដោយទំនុកចិត្ត និង ក្តីស្រឡាញ់។



## ក្រសួងបរិស្ថាន

## ស្ថាប័នរដ្ឋនិងឯកជនទាំងពីរផ្តើមធ្វើការងារលើហេតុនៃផលប៉ះពាល់បរិស្ថានជាផ្លូវការនៅឆ្នាំ២០១៧នេះ

ប្រធានបទបរិស្ថានត្រូវបានគេយកចិត្តទុកដាក់យ៉ាងខ្លាំងនៅទូទាំងសកលលោកនាពេលបច្ចុប្បន្ននេះ។ ដើម្បីឆ្លើយតបនឹងប្រធានបទសកលនេះ និង ដើម្បីជួយសម្រួលដល់ការលំបាកនានារបស់សមាជិករោងម៉ាស៊ីនកិនស្រូវពាក់ព័ន្ធបញ្ហាបរិស្ថាន សហព័ន្ធស្រូវអង្ករកម្ពុជាបានសម្រេចចិត្តបោះមួយជំហានទៅមុខទៀត គឺការធ្វើការងារជាមួយក្រសួងបរិស្ថានក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

សហព័ន្ធស្រូវអង្ករកម្ពុជា និង ក្រសួងបរិស្ថានបានសម្រេចជាផ្លូវការនូវអនុស្សរណៈយោគយល់គ្នាមួយ ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន កាលពីថ្ងៃទី៧ខែតុលាឆ្នាំ២០១៦ ដើម្បីធ្វើការងារបរិស្ថានដែលជាហេតុផលសំខាន់មួយក្នុងការទាក់ទាញទំនុកចិត្តពីអ្នកប្រើប្រាស់ទាំងក្នុងប្រទេសនិងអន្តរជាតិ និង ជាហេតុផលសម្រាប់ការចូលរួមការអភិវឌ្ឍប្រកបដោយនិរន្តរភាព មិនប៉ះពាល់ដល់បរិស្ថាន។

**ឯកឧត្តម សាយ សំអាល់** បានកោតសរសើរចំពោះសហព័ន្ធស្រូវអង្ករកម្ពុជាចំពោះការស្ម័គ្រចិត្តចូលរួមការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ សួរស័ព្ទនៃការកោតសរសើរនេះត្រូវបានគេឮ ក្នុងឱកាសនៃការចុះហត្ថលេខាជាផ្លូវការលើអនុស្សរណៈនៃការយោគយល់គ្នារវាងក្រសួងបរិស្ថាន និង សហព័ន្ធស្រូវអង្ករកម្ពុជា ក្រោមអធិបតីភាព ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន និង **ឯកឧត្តម សុខ ពុទ្ធីវុធ** ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា។

នាពេលនោះ ឯកឧត្តម សាយ សំអាល់ បានពន្យល់ថា នៅក្នុងអាណត្តិនេះក្រសួងបរិស្ថានភាពមានភាពមមាញឹកខ្លាំងក្នុងការចុះវាយតម្លៃពីហេតុប៉ះពាល់បរិស្ថាន ហើយ ឯកឧត្តម អរគុណដល់សហព័ន្ធស្រូវអង្ករកម្ពុជា ដែលបានចូលរួមដោយស្ម័គ្រចិត្តរត់រកក្រសួងបរិស្ថានសម្រាប់ជំរុញការងារនេះ ដោយសារថាកន្លងមកក្រសួងបរិស្ថានលំបាកក្នុងការពន្យល់ដើម្បីឲ្យមានការចូលរួមពាក់ព័ន្ធបរិស្ថាននេះ។

ឯកឧត្តម មានប្រសាសន៍ថា៖ «ពីមុនយើងតែងតែរត់ទៅរកគេ ដើម្បីឲ្យមានការចូលរួម ឥឡូវ [សហព័ន្ធស្រូវអង្ករកម្ពុជា] ស្ម័គ្រចិត្តចូលរួម។ ចឹងទេ យើងខ្ញុំសប្បាយចិត្តណាស់។ យើងសង្ឃឹមថា ថ្ងៃក្រោយ នឹងមានវិស័យផ្សេងៗទៀត ចូលរួមជាមួយក្រសួងបរិស្ថានយើងខ្ញុំ ដើម្បីឲ្យយើងធ្វើការងារទាំអស់គ្នា»។

តាមរយៈការគិតគូរបរិស្ថានជាចំបងនេះ ឯកឧត្តមរដ្ឋមន្ត្រី រំពឹងថា ផលិតផលអង្ករកម្ពុជានឹងទទួលបានការសាទរ ការជឿទុកចិត្តពីសំណាក់អ្នកប្រើប្រាស់ និងជួយលើកកម្ពស់ផលិតផលអង្ករទាំងក្នុងកម្រិតជាតិនិងអន្តរជាតិ។

ជាមួយគ្នានោះដែរ ឯកឧត្តម សុខ ពុទ្ធីវុធ ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា បានថ្លែងថា អនុស្សរណៈថ្មីនេះ នឹងជួយសមាជិករបស់សហព័ន្ធស្រូវអង្ករកម្ពុជា តាមរូបភាពជាច្រើនក្នុងសង្វាក់ផលិតកម្មស្រូវអង្ករ។

ឯកឧត្តម ថ្លែងថា៖ «សម្រាប់អនុស្សរណៈយោគយល់គ្នានេះ យើងជឿជាក់ថា វានឹងជួយសម្រួលដល់រោងម៉ាស៊ីនបានមួយកម្រិតទៀត ទាក់ទងថ្លៃដើមរបស់យើង តាមរយៈការកាត់បន្ថយពេលវេលា ការកាត់បន្ថយការចំណាយថវិកា ការទទួលប្រឹក្សាបច្ចេកទេសចំពោះការរៀបចំនិងគ្រប់គ្រងបរិស្ថានជាដើម»។

ឯកឧត្តម បន្ថែមថា៖ «ជាមួយគ្នានេះ វាក៏អាចជួយជំរុញផងដែរដល់ការចូលរួមដល់ការពារបរិស្ថានប្រកបដោយនិរន្តរភាពតាមរយៈការរៀបចំកិច្ចសន្យា ការពារបរិស្ថាន ភ្ជាប់ជាមួយផែនការគ្រប់គ្រងបរិស្ថានឲ្យបានច្បាស់លាស់សម្រាប់គម្រោងនានាក្នុងការកែច្នៃអង្ករនៅកម្ពុជា។

***អនុស្សរណៈដែលភាគីទាំងពីរបានចុះហត្ថលេខារួមគ្នាក្នុងពេលកន្លងមកនេះមានគោលបំណង និង វិសាលភាពដូចខាងក្រោម៖***

**គោលបំណង៖**

- អនុវត្តគោលនយោបាយនៃការនាំចេញអង្ករឲ្យបាន០១លានតោនក្នុងមួយឆ្នាំរបស់រាជរដ្ឋាភិបាលកម្ពុជា
- ជំរុញការលើកទឹកចិត្តដល់កសិករ សហគ្រិន និង វិនិយោគិនក្នុងការផលិតអង្ករ និង ប្រកួតប្រជែងសម្រាប់ការនាំចេញអង្ករទៅក្រៅប្រទេស
- បង្កើនគុណភាពអង្ករនៅកម្ពុជាដែលគ្មានជាតិគីមី និង មានការជឿជាក់ពីអតិថិជន
- ធានាការចូលរួមអភិវឌ្ឍន៍ រោងចក្រម៉ាស៊ីនកិនស្រូវ និងកែច្នៃអង្ករ ប្រកបដោយនិរន្តរភាពបរិស្ថាន។

**វិសាលភាព៖**

អនុស្សរណៈនៃការយោគយល់គ្នានេះ មានវិសាលភាពអនុវត្តសម្រាប់ប្រភេទគម្រោងបង្កើតរោងចក្រម៉ាស៊ីនកិនស្រូវ និង កែច្នៃអង្ករនៅព្រះរាជាណាចក្រកម្ពុជា ដែលតម្រូវឲ្យរៀបចំកិច្ចសន្យាការពារបរិស្ថាន ដោយភ្ជាប់ជាមួយនូវផែនការគ្រប់គ្រងបរិស្ថាន។

**ទំនួលខុសត្រូវសំខាន់ៗរបស់ភាគីទាំងពីរលើការងារអនុវត្តហេតុប៉ះពាល់បរិស្ថាន។**





## ក្រសួងសាធារណការនិងដឹកជញ្ជូន

## សហព័ន្ធស្រូវអង្ករកម្ពុជាលើកសំណើរដល់ក្រសួងជួយដោះស្រាយ

ថ្ងៃទី២៨-២៩ ខែធ្នូ ឆ្នាំ២០១៦ សហព័ន្ធស្រូវអង្ករកម្ពុជា បានចូលរួមមហាសន្និបាតបូកសរុបការងារឆ្នាំ២០១៦ និងលើកទិសដៅឆ្នាំ២០១៧ របស់ក្រសួងសាធារណៈការនិងដឹកជញ្ជូន ក្រោមអធិបតីភាព ឯកឧត្តម ទេសរដ្ឋមន្ត្រី **ស៊ុន ចាន់ថុល** រដ្ឋមន្ត្រីក្រសួងសាធារណៈការនិងដឹកជញ្ជូន។

សហព័ន្ធស្រូវអង្ករកម្ពុជាបានលើកឡើងនូវសំណូមពរមួយចំនួនដើម្បីដោះស្រាយពីបញ្ហាកង្វល់ផ្សេងៗរបស់ សមាជិកសម្រាប់វិស័យស្រូវអង្ករកម្ពុជាលើបញ្ហាវិស័យដឹកជញ្ជូនដើម្បីជួយសម្រួលការដឹកជញ្ជូនការធ្វើពាណិជ្ជកម្មអោយកាន់តែប្រសើរឡើង ដើម្បីជម្រាបជូនក្រសួងក៏ដូចជារដ្ឋាភិបាលពិនិត្យ និងដោះស្រាយតាមរយៈផែនការឆ្នាំ២០១៧ និងឆ្នាំបន្តបន្ទាប់ទៀត ក្នុងពេលធ្វើបទអន្តរាគមន៍របស់សហព័ន្ធ។

*សំណូមពរទាំងនោះរួមមាន៖*

១-ស្នើសុំក្រសួងសាធារណៈការនិងដឹកជញ្ជូន ពង្រីកមធ្យោបាយដឹកជញ្ជូនបានឲ្យសម្បូរបែប ខណៈដែលបច្ចុប្បន្ននេះ ការដឹកជញ្ជូនពឹងផ្អែកខ្លាំងបំផុត លើផ្លូវថ្នល់ ខណៈដែលផ្លូវដែក និង ផ្លូវទឹកសុទ្ធតែជាសក្តានុពលខ្លាំងសម្រាប់ការដឹកជញ្ជូនផលិតផល តែកម្ពុជាមិនទាន់ប្រើប្រាស់បានប្រកបដោយប្រសិទ្ធភាពនៅឡើយ។ ការបង្កើតមធ្យោបាយដឹកជញ្ជូនច្រើន អាចធ្វើឲ្យតម្លៃដឹកជញ្ជូនមានការប្រកួតប្រជែង និងផ្តល់ជម្រើសកាន់តែច្រើន ដល់អ្នកប្រើប្រាស់សេវាដឹកជញ្ជូន។

២-ស្នើសុំក្រសួងពង្រីកមធ្យោបាយដឹកជញ្ជូនតាមផ្លូវគោកបន្ថែមទៀត ពិសេសពង្រីកផ្លូវសំខាន់ៗ ដូចជាផ្លូវជាតិលេខ១ លេខ៥ ជាដើម ដើម្បីឲ្យការដឹកជញ្ជូនបានឆាប់រហ័ស កាត់បន្ថយពេលវេលា។

៣- ស្នើសុំក្រសួងជួយពង្រីកមធ្យោបាយដឹកជញ្ជូនតាមខេត្ត ពិសេសការដឹកជញ្ជូន តាមផ្លូវទឹកពីស្រែរបស់បងប្អូនកសិករ ដល់ឃ្លាំងស្តុកស្រូវឬរោងម៉ាស៊ីន ដើម្បីសម្រួលថ្លៃដើម។

៤- ស្នើសុំក្រសួងអន្តរាគមន៍ជាប្រព័ន្ធ ឬរូបមន្តណាមួយជួយបញ្ចុះតម្លៃ Forwarding fee ដែលតាមការសិក្សា របស់អង្គការJICA រកឃើញថាមានតម្លៃខ្ពស់ជាងប្រទេសជិតខាង។



លោក ហ៊ាន ធារ៉ា មន្ត្រីជាន់ខ្ពស់លេខាធិការដ្ឋានសហព័ន្ធ ឡើងថ្លែងក្នុងសន្និបាតក្រសួង

ជាការឆ្លើយតប ឯកឧត្តម ទេសរដ្ឋមន្ត្រី **ស៊ុន ចាន់ថុល** បានទទួលស្គាល់ពីភាពលំបាកក្នុងពេលកន្លងមករបស់សហព័ន្ធស្រូវអង្ករកម្ពុជា ដោយសារកត្តាតម្លៃខ្ពស់ក្នុងសង្វាក់ផលិតកម្ម ក្នុងនោះក៏មានមធ្យោបាយដឹកជញ្ជូនផងដែរ ដោយឯកឧត្តម ទេសរដ្ឋមន្ត្រី បានគូសបញ្ជាក់ថា អង្ករកម្ពុជាមានសក្តានុពលនាំចេញទៅកាន់ទីផ្សារអឺរ៉ុប ដោយសារអង្ករកម្ពុជាទទួលបានការអនុគ្រោះលើកលែងពន្ធតាមរយៈគម្រោង EBA ដែលធ្វើឲ្យអង្ករកម្ពុជាចំណេញរហូតដល់១៧០ដុល្លារក្នុងមួយតោន។

ឯកឧត្តម ទេសរដ្ឋមន្ត្រី ស៊ុន ចាន់ថុល មានប្រសាសន៍៖«សំខាន់ណាស់ EBA ព្រោះយើងទទួលបាន១៧០ដុល្លារក្នុងមួយតោន។ បើអត់វាទេ យើងលំបាកមែនទែនហើយ។ នេះខ្ញុំរាយការបន្ថែមជូនអង្គសន្និបាតឲ្យយល់ អំពីការលំបាករបស់សហព័ន្ធស្រូវអង្ករកម្ពុជាក្នុងការនាំចេញអង្ករទៅលក់នៅឯបរទេស។ យើងចូលរួមទាំងអស់គ្នាដើម្បីជួយកសិករយើង។ បើយើងលក់អង្ករបានច្រើន កសិករយើងនឹងមានជីវភាពធូរធាជាងមុនផងដែរ»។

ជាមួយការស្នើឲ្យស្ថាប័នជាច្រើនយល់ពីការលំបាករបស់សហព័ន្ធស្រូវអង្ករកម្ពុជា ឯកឧត្តម ទេសរដ្ឋមន្ត្រី ស៊ុន ចាន់ថុល ក្នុងនាមថ្នាក់ដឹកនាំក្រសួងសាធារណៈការនិងដឹកជញ្ជូន បានសន្យាយ៉ាងឧឡារិកក្នុងអង្គសន្និបាតរបស់ក្រសួងក្នុងពេលកន្លងទៅនេះថា ឯកឧត្តម នឹងខិតខំកសាងស្ថាបនាមធ្យោបាយដឹកជញ្ជូនថែមទៀត ដើម្បីរួមចំណែកដល់ការកាត់បន្ថយថ្លៃដើមក្នុងវិស័យស្រូវអង្ករនេះ។

ឯកឧត្តម ទេសរដ្ឋមន្ត្រី បញ្ជាក់ថា៖ «យើងខ្ញុំសន្យាគិតគូរយ៉ាងណា រៀបចំបញ្ចុះតម្លៃដឹកជញ្ជូន ដូចជាការសាងសង់ផ្លូវ ក៏ដូចជាតាមផ្លូវទឹក និងតាមផ្លូវដែក»។

## ទំនាក់ទំនងស្ថាប័នអន្តរជាតិ

## ការទទួលភ្ញៀវពីសហភាពអឺរ៉ុបក្នុងការចុះទស្សនកិច្ចសហគមន៍កសិកម្ម ( សទ្ធារផល ) និងរោងម៉ាស៊ីននៅខេត្តបាត់ដំបង

នៅពេលដែលការនាំចូលអង្ករពីប្រទេសកម្ពុជាមានការកើនឡើងខ្លាំងនាពេលប៉ុន្មានឆ្នាំចុងក្រោយនេះតាមរយៈE B A ដែលធ្វើអោយកម្ពុជារួចពន្ធនាំចូលមានការត្អូញត្អែរពីប្រទេសនាំចេញអង្ករដែលជាសមាជិកសហភាពអឺរ៉ុបខ្លះអំពីការប៉ះពាល់ដល់ ផលិតកម្មស្រូវអង្ករនៅប្រទេសគេ។

ដើម្បីពិភាក្សានិងត្រួតពិនិត្យពីបញ្ហានេះ ប្រតិភូអឺរ៉ុប បានមកទស្សនកិច្ចនៅកម្ពុជា។ **ឯកឧត្តម សុខ ពុទ្ធិវុធ** និងក្រុមការងារបានទទួលស្វាគមន៍ និងបានរួមដំណើរដល់ប្រតិភូទៅទស្សនកិច្ចដល់វាលស្រែកសិករ ដែលខិតខំផលិតស្រូវដ៏មានគុណភាពខ្ពស់ រោងម៉ាស៊ីនកិនស្រូវរបស់កម្ពុជាដែលមានស្តង់ដារអន្តរជាតិ។

ជាមួយគ្នានេះយើងបានបង្ហាញពីការខិតខំរបស់យើងក្នុងការធ្វើទំនើបកម្មវិស័យស្រូវអង្ករ ក៏ដូចជាការពង្រីកទីផ្សារទៅកាន់ប្រទេសផ្សេងៗនៅលើពិភពលោក។ ជាមួយគ្នាស្រូវក្រអូបប្រណីតរបស់កម្ពុជាដែលនាំចូលទៅអឺរ៉ុប ជាប្រភេទស្រូវដោយឡែក ខុសពីប្រភេទស្រូវរបស់អឺរ៉ុប ដែលការនាំចូលរបស់កម្ពុជាមិនប៉ះពាល់ខ្លាំងដល់ផលិតកម្មស្រូវនៅអឺរ៉ុប។



រូបភាព៖ រោងម៉ាស៊ីនរបស់ក្រុមហ៊ុន City Rice Import Export Co., Ltd

## ការប្រមូលតម្លៃស្រូវប្រចាំសប្តាហ៍

ក្រោយពីការផ្ទុះការតវ៉ាពីសំណាក់កសិករនៅក្នុងស្រុកសង្កែរខេត្តបាត់បងកាលពីខែតុលាឆ្នាំ២០១៦ ដោយសារការធ្លាក់ថ្លៃស្រូវយ៉ាងគំហុកក្នុងរយៈពេលតែប៉ុន្មានថ្ងៃ មានការសន្និដ្ឋាននិងផ្តល់ហេតុផលច្រើនលើរឿងនេះ តែសហព័ន្ធស្រូវអង្ករកម្ពុជាដឹងច្បាស់ថា ការចែករំលែកព័ត៌មានមិនបានរហ័ស ពិតជាមានសារៈសំខាន់ទៅដល់អ្នកពាក់ព័ន្ធដើម្បីឲ្យជួយដោះស្រាយ។

ចាប់តាំងពីពេលនោះមក សហព័ន្ធស្រូវអង្ករកម្ពុជា បានចាត់បុគ្គលិកលេខាធិការដ្ឋាន្ទ សម្រាប់តាមដានតម្លៃស្រូវជាប្រចាំរៀងរាល់សប្តាហ៍ ទៅតាមប្រភេទស្រូវ និង ទីតាំងជាក់ស្តែង។

ចាប់តាំងពីការប្រមូលព័ត៌មាននិងចែកចាយព័ត៌មាននោះ នៅក្នុងចំណោមអ្នកពាក់ព័ន្ធ ជាពិសេសរោងម៉ាស៊ីនកិនស្រូវ បានប្រើប្រាស់វាយ៉ាងមានប្រសិទ្ធភាព ដើម្បីតាមដានហាងឆេងស្រូវផង និង ដើម្បីដោះស្រាយតាមរយៈការទិញនៅតំបន់ណាដែលមានស្រូវកំពុងតែមានបញ្ហា។

តារាងតំលៃស្រូវ (Paddy Price) ត្រូវបានបង្ហាញជាសាធារណៈជាប្រចាំតាមរយៈបណ្តាញសង្គម ហ្វេសប៊ុក និង គេហទំព័ររបស់សហព័ន្ធដូចខាងក្រោម៖ https://www.facebook.com/cambodiaricefederation/ http://www.crf.org.kh/

*តារាងតំលៃស្រូវ (Paddy Price) ត្រូវបានធ្វើការប្រមូល និងផ្សព្វផ្សាយពីតំលៃស្រូវប្រចាំ ចំពោះខេត្តមួយចំនួនដែលសំបូរការដាំដុះស្រូវ។*

***ខាងក្រោមនេះជាតារាងបង្ហាញពីដំណើរតម្លៃស្រូវនៅខេត្តដែលសម្បូរស្រូវ!***

**សហព័ន្ធស្រូវអង្ករកម្ពុជា**

Cambodia Rice Federation

**តម្លៃស្រូវ (សើម)នៅរោងម៉ាស៊ីន**

(តម្លៃគិតជា ៛/១គ.ក)




## ការតាមដានតម្លៃអង្ករនៅតាមមាត់ច្រកនាំចេញ (FOB)

## ការតាមដានតម្លៃអង្ករនាំចេញ (FOB)

នៅក្នុងត្រីមាសទី៤ឆ្នាំ២០១៦ សហព័ន្ធស្រូវអង្ករកម្ពុជា បានផ្តួចផ្តើមឲ្យមានការប្រមូលទិន្នន័យតម្លៃអង្ករនាំចេញនៅត្រង់មាត់ច្រកនាំចេញ (FOB) ដើម្បីបានជាមូលដ្ឋានក្នុងការប្រៀបធៀបតម្លៃដើម។

ភាគីពាក់ព័ន្ធនៅក្នុងប្រតិបត្តិការនាំចេញអង្ករទៅកាន់ទីផ្សារបរទេស បានមើលឃើញនូវអត្ថប្រយោជន៍នៃទិន្នន័យនេះ ដែលត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយក្នុងចំណោមអ្នកនាំចេញអង្ករទាំងអស់ ដើម្បីតាមដានតម្លៃនាំចេញ និង ប្រភេទអង្ករដែលកម្ពុជានាំចេញ។

យោងតាមស្ថិតិដែលក្រុមការងារលេខាធិការដ្ឋានសហព័ន្ធស្រូវអង្ករ តាមដាននិងស្រង់ជាប្រចាំ តម្លៃអង្ករអង្ករក្រអូបមានការប្រែប្រួលខ្លាំងជាងតម្លៃអង្ករប្រភេទផ្សេងៗទៀត។ តម្លៃអង្ករក្រអូបបានធ្លាក់ចុះជាង១០០ដុល្លារក្នុងមួយតោន ធៀបពីដើមត្រីមាសទី១រហូតដល់ដំណាច់ត្រីមាសទី៤ ខណៈតម្លៃអង្ករប្រភេទផ្សេងៗ បានប្រែប្រួលតិចតួចទៅរកកំណើន។

*ក្រាហ្វិកខាងក្រោមនេះជាតារាងតម្លៃអង្ករ (FOB) ដែលក្រុមការងាររបស់លេខាធិការដ្ឋានបានស្រង់ ដោយលើកយកក្នុងរយៈពេលត្រីមាសទី៤៖*

# សហព័ន្ធស្រូវអង្ករកម្ពុជា

CAMBODIA RICE FEDERATION

CAMBODIAN WEEKLY FOB INDICATION PRICE



# ទិន្នន័យនាំចេញអង្ករឆ្នាំ ២០១៦

## ស្ថិតិនៃការនាំចេញអង្ករ ឆ្នាំ២០១៦

### បរិមាណនៃការនាំចេញ ឆ្នាំ២០០៩-២០១៦

Export amount Year 2009-2016




### ភាគរយនៃអង្ករនាំចេញនៅឆ្នាំ២០១៦ ទៅតាមប្រភេទ

Percentage of Rice Export by Variety in 2016









## *Making Rice More Nutritious – Commercial and Public Health Opportunities*

Rice fortification offers the opportunity to make rice more nutritious post-harvesting by adding essential vitamins and minerals to milled rice. There are three key reasons why adding vitamins and minerals to rice is beneficial from both a public health and commercial perspective:

1) Market growth and higher profitability for branded specialty rice products

2) Impact of Nutrition – a growing number of countries are making rice fortification mandatory or introducing fortified rice in social safety net programs, as supported by UN agencies, governments, and NGOs to improve public health

3) Growing health concerns connected to high rice consumption of rice, especially the commonly consumed white rice; namely type 2 diabetes, low fiber intake, and low nutritional value.

Fortification of wheat and maize flour, as well as salt iodization has been done for decades to make people healthier, more productive and smarter. Adding essential nutrients to wheat and maize flour is mandatory in over 80 countries worldwide.



48% industrially milled maize flour is fortified



30% industrially milled wheat flour is fortified



1% industrially milled rice is fortified

As of 2016, 5 countries and 6 U.S. states have mandatory rice fortification. Globally, 1% of the milled rice for human consumption contains added vitamins and minerals. Due to the three trends listed above, athe strong evidence base supporting rice fortification and technological developments in this field, there is large momentum for rice fortification to grow. Milled rice is a poornot a rich source of vitamins and minerals yet it represents more than half of the daily energy and protein intake for 3 billion people worldwide. The potential impact of rice fortification to address deficiencies and offer new healthy rice-based products is hugeenormous.

A key technology to make rice more nutritious is extrusion. Extrusion is also used to make pasta, congee and many other food products. The effectiveness of adding nutrients to rice with via extrusion technology is supported by over 18 scientific publications.






*Extruded fortified kernels in the form of rice grains which are blended into regular rice to produce fortified rice*

The 2-step process to make rice more nutritious with via extrusion is as follows:

Broken rice is grinded into rice flour and mixed with vitamins and minerals. This mix is then passed through an mix goes through the extruder, which forms little 'vitamin and mineral pills' in the shape and color of a rice grain. These so-called vitamin and mineral kernels are finally mixed into regular rice in a 0,5 – 2% ratio to produce more nutritious rice. Many different concepts are possible, including new branded rice concepts for mothers, beauty rice, vegetarians, healthy digestion, etc.

The fortified rice cooks the same, tastes the same and can look the same as regular rice.

In Cambodia, a large study among schoolchildren confirmed that fortified rice can effectively improve the vitamin status of children and have a positive impact on their cognitive development; the children receiving the fortified rice performed better at school then the children receiving regular rice. Based on these results published between 2014 and 2016, the Government of Cambodia supports the use of fortified rice inat schools. The UN World Food Programme now ensures many schools in Cambodia receive fortified rice during their school meal.

DSM is the key partner for rice millers, traders and processors, interested in making their rice more nutritious. As the global leader in vitamins and mineral premixes, DSM supplies fortified kernels as well as quality vitamin and mineral blends to fortify rice and launch new branded rice concepts.

The potential health impact of fortified rice is vast, as well as the commercial opportunities to launch healthier and easy-to-use rice products both in Cambodia and globally.

For further information please contact Judith Smit (Judith.smit@dsm.com)



SMWaypoint
PRECISION
REMOTE
SENSING

# ការបង្កបង្កើនទិន្នផលដំណាំ

ជួយកាត់បន្ថយការចំណាយ និង ពេលវេលាយ៉ាងមានប្រសិទ្ធភាព




យន្តហោះគ្មានមនុស្សបើក (Drone ) គឺជាបច្ចេកវិទ្យាទំនើបជំនាន់ថ្មី មានសមត្ថភាពខ្ពស់ត្រូវបានក្រុមហ៊ុន SMWaypoint Co.,Ltd យកមកប្រើប្រាស់ក្នុងការជួយសម្រួលដល់វិស័យកសិកម្ម និងកសិឧស្សាហកម្ម ដូចជា ដំណាំស្រូវ កៅស៊ូ ពោត សណ្តែក ដំឡូងមី ស្វាយចន្ទី អំពៅ ម៉ែសាក់ និងដំណាំផ្សេងៗជាច្រើនទៀត។ វាមានសារៈសំខាន់ក្នុងការត្រួតពិនិត្យ រាល់ជម្ងឺ ឬ បញ្ហាផ្សេងៗរបស់ដំណាំនូវដំណាក់កាលដំបូង ដើម្បីបង្ការការរីករាលដាលខ្លាំងដែលអាចបង្កផលប៉ះពាល់ដ៏ធ្ងន់ធ្ងរដល់ដំណាំ។ ជាពិសេសយើងអាចជួយក្នុងការរៀបចំសណ្ឋានដី ប្រព័ន្ធធារាសាស្រ្ត និងផ្នែកផ្សេងៗទៀតដែលផ្តល់ភាពងាយស្រួលក្នុងការគ្រប់គ្រងផ្ទៃដីដាំដំណាំ។

**ការវិភាគដំណាក់កាលដំបូង**
ការវិភាគលើកដំបូងត្រឹមត្រូវនិងការកំណត់នៃការគំរាមកំហែងដល់ដំណាំគឺជាចំនុចសំខាន់នៃការសំរេចចិត្តដ៏ត្រឹមត្រូវ

**ភាពមើលឃើញ**
យើងអាចធ្វើការថតនៅតំបន់ដែលពិបាកទៅដល់និងគ្រោះថ្នាក់

**ភាពសុក្រឹត**
កំណត់ទីតាំង និងកន្លែងដែលមានបញ្ហាប្រឈមជាមួយនឹងកូអរដោនេជាក់លាក់

**វិភាគទិន្នន័យ**
វិភាគទិន្នន័យដោយស្វ័យប្រវត្តិព្រមជាមួយនិងគុណភាពខ្ពស់ដែលជួយក្នុងការកាត់បន្ថយផលរំខានផ្សេងៗ

+855(0) 23 967 772 +855(0)89 877 788
info@smwaypoint.com
www. smwaypoint.com
Address: #2C, Street 120, Sangkat Phsar Thmey II






## NIKOLINE RICE MILL

- Established in 2010 and continue to provide only the best quality rice from Cambodia.
- Cap: 50,000Mt/year
- Products:
  - . **JASMINE RICE**
  - . **FRAGRANT RICE (SEN KRA OB)**
  - . **LONG GRAIN WHITE RICE**
  - . **Brown Rice BROWN RICE**
- Packaging:
  - + 1 - 10kg (Vacuumed & Non vacuumed)
  - + 10 - 50kg PP or PP+PE Bag
  - + Jumbo & Liner Bag







**CONTACT:**
**Mr. NORNG VEASNA,** Director of Sales, Mobile: (+855) 12 400 112 (available on what's app & LINE), rice.veasnanorng@gmail.com
**Mr. HONG NIKOLINE,** Mobile: (+855) 77 777 708 Email: nikoline@nklrice.com
**Mr. VINH CHEANG,** Mobile: (+855) 12 933 737 Email: v.cheang7ricemill@gmail.com

**PHNOM PENH Office:** #17, Street 334, Sangkat Beoung Kengkang 1, Khan Chamkamorn, Phnom Penh, CAMBODIA
**Mill: V**eal Kangdeang Village, Chup Commune, Tboung Khmum District, Tboung Khmum Province, CAMBODIA

**Visit us: www.nikoline.com.kh**